រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

ផ្នែកបុរាណវត្ថុវិទ្យា

# ប្រាសាទរកឃើញថ្មីៗ និងការធ្វើផែនទីស្ថានីយបុរាណ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



ផុន កសិកា

២០១២

**សមាសភាពមន្ត្រីសិក្សាស្រាវជ្រាវ៖**

លោក ផុន កសិកា
លោក ហឿង សុជារស់
លោក ជ័យ រតនា
លោក ឃិន សាវន់
កញ្ញា ជុំ វិជ្ជតា

**ចូលរួមសហការស្រាវជ្រាវ ដោយ៖**

លោក ផុន ជាកុសល
លោក ជឿន សុខុន
លោក ឡេង សត្យា
លោក ឡេង វិទ្យា
លោក ឡេង វិទូ

**ទីប្រឹក្សាបច្ចេកទេស**

១. លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

២. ឯកឧត្តម **ជុច ភឿន** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិព្រះវិហារ និងជាទីប្រឹក្សាបច្ចេកទេសនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា។

៣. ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ។

៤. ឯកឧត្តមបណ្ឌិតរដ្ឋ **តេច សំណាង** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាទីប្រឹក្សាបច្ចេកទេស នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា។

**គណៈកម្មការត្រួតពិនិត្យគម្រោងស្រាវជ្រាវ**

| | | |
|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **នូ ចាន់សុធី** | ប្រធាន |
| ២. | ឯកឧត្តម **លី សុធីរត្ន័** | សមាជិក |
| ៣. | លោក **ផុន កសិកា** | សមាជិក |

## សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំជាមន្ត្រីស្រាវជ្រាវនៃផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជបណ្ឌិត្យសភាកម្ពុជាដែលបានគាំទ្រ និងឧបត្ថម្ភថវិកាដល់គម្រោងស្រាវជ្រាវនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះមន្ត្រីបម្រើការក្នុងផ្នែករដ្ឋបាលនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានជួយសម្របសម្រួលរាល់លិខិតរដ្ឋបាលផ្សេងៗ ដើម្បីឲ្យគម្រោងនេះអាចដំណើរការបានតាមពេលវេលាកំណត់។ ឆ្លៀតឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលបានអនុញ្ញាត និងបញ្ជូនមន្ត្រីនៅមូលដ្ឋានចូលរួមសហការស្រាវជ្រាវ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអាជ្ញាធរដែនដី ចាប់តាំងពីឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យដែលបានគាំទ្រ និងជួយសម្រួលរាល់លិខិតចុះសិក្សាស្រាវជ្រាវ ជាងនេះទៀតអភិបាលស្រុក និងអភិបាលរងស្រុកត្រពាំងប្រាសាទ ព្រមទាំងមេឃុំ មេប៉ុស្តិ៍ មេភូមិ ក្នុងស្រុកត្រពាំងប្រាសាទទាំងអស់ដែលបានចូលរួមសហការ ព្រមទាំងបានចូលរួមដំណើរ បង្ហាញផ្លូវ នាំមន្ត្រីស្រាវជ្រាវយើងទៅដល់ទីតាំងស្ថានីយ និងប្រាសាទដែលមានចម្ងាយឆ្ងាយ និងផ្លូវពិបាកធ្វើដំណើរ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់សមាជិកស្រាវជ្រាវ និងអស់លោកដែលបានចូលរួមសហការស្រាវជ្រាវទាំងអស់ បានចូលរួមសិក្សាស្រាវជ្រាវរហូតទទួលលទ្ធផលជោគជ័យ។ លទ្ធផលនេះអាចទទួលបានដោយសារការខិតខំប្រឹងប្រែង មិនខ្លាចឧបសគ្គប្រឈមទាំងឡាយ ដូចជា បញ្ហាផ្លូវពិបាកធ្វើដំណើរ កំដៅថ្ងៃក្ដៅ ជាដើម។ ជាពិសេសនោះ លទ្ធផលទទួលបានដោយការមុះមុតមិនរាថយចំពោះទីតាំងដែលនឹងអាចមានគ្រោះថ្នាក់ដោយសារជាទីតាំងធ្លាប់មានការប្រយុទ្ធគ្នារវាងកងទ័ពរាជរដ្ឋាភិបាលនៃអតីតរដ្ឋកម្ពុជា និងអតីតកងទ័ពខ្មែរក្រហម។ ទីតាំងនោះនៅមានអាវុធជាតិផ្ទុះ ដូចជាមីន ជាដើម។

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ.................................................... I

មាតិកា.................................................... II

បញ្ជីរូបភាព.................................................... V

បញ្ជីផែនទី និងប្លង់ប្រាសាទ.................................................... VIII

I.សេចក្តីផ្តើម.................................................... ១

គោលបំណងនិងអត្ថប្រយោជន៍នៃគំរោង.................................................... ២

វិធីសាស្ត្រស្រាវជ្រាវ.................................................... ៣

II.ប្រវត្តិស្រុកត្រពាំងប្រាសាទ.................................................... ៥

III.ប្រាសាទ និងស្ថានីយបុរាណរកឃើញថ្មីៗក្នុងស្រុកត្រពាំងប្រាសាទ.................................................... ៧

ក. ឃុំត្រពាំងប្រាសាទ.................................................... ៨

១. ប្រាសាទត្រពាំងប្រាសាទខាងត្បូង.................................................... ៨

២. ប្រាសាទត្រពាំងប្រាសាទខាងជើង.................................................... ១៣

៣. ប្រាសាទរលំទឹកខ្មៅ.................................................... ១៨

៤. ត្រើះប្រាសាទអូរសោម.................................................... ២០

៥. ប្រាសាទរលំឆ្កោ.................................................... ២២

៦. ប្រាសាទអូរចំបក់.................................................... ២៤

៧. ប្រាសាទតាគុញ.................................................... ២៦

៨. ប្រាសាទល្បើកក្រៃ.................................................... ២៨

៩. ប្រាសាទភូនចិន.................................................... ៣០

១០. ប្រាសាទជិតប្រាសាទភូនចិន .................................................... ៣២

១១. ប្រាសាទត្នំសណ្តាក.................................................... ៣៤

១២. ប្រាសាទចាក់ក្រែង.................................................... ៣៧

១៣. ទួលប្រាសាទភូមិថ្កូវ ឬទួលប្រាសាទភូមិអភិវឌ្ឍថ្មី.................................................... ៣៩

១៤. ស្ថានីយយកថ្មបាយក្រៀម.................................................... ៤១

១៥. ស្ថានីយយកថ្មតក់ និងសិប្បកម្មចម្លាក់ថ្មតក់.................................................... ៤៣

១៦. ស្ថានីយយកថ្មបាយក្រៀមនៅភ្នំសណ្ដក........................................ ៤៤
១៧. ថ្មគោល នៅជិតស្ថានីយយកថ្មបាយក្រៀមភូមិពានមាស........................ ៤៥
១៨. ថ្មគោល នៅជិតប្រាសាទល្បើកវ៉ៃ........................................ ៤៧

ខ. ឃុំអូរស្វាយ........................................ ៥១
១៩. ប្រាសាទអូរស្វាយ........................................ ៥១
២០. ប្រាសាទត្រពាំងបី........................................ ៥៣
២១. ទួលប្រាសាទនំនប់អតិទឡ្ហន៍........................................ ៥៤
២២. ប្រាសាទទួលគ្រួស........................................ ៥៥
២៣. ថ្មគោលក្នុងភូមិទួលគ្រួស........................................ ៥៦

គ. ឃុំផ្អាវ........................................ ៥៨
២៤. ទួលភូមិបុរាណ និងត្រពាំងបុរាណ........................................ ៥៨

ឃ. ឃុំបាក់អន្លូង........................................ ៦០
២៥. ទួលប្រសើរ........................................ ៦០

ង. ឃុំនំនប់ដាច់........................................ ៦១
២៦. ទួលប្រាសាទចារ........................................ ៦១
២៧. ប្រាសាទនំនប់ដាច់........................................ ៦៣
២៨. ទួលប្រាសាទត្រពាំងពោធិ៍........................................ ៦៥

ច. ឃុំប្រឡាយ........................................ ៦៨
២៩. ប្រាសាទក្រហម........................................ ៦៨
៣០. ទួលត្រាំចាន........................................ ៧០
៣១. ប្រាសាទត្រពាំងនឹម ........................................ ៧២
៣២. ប្រាសាទស្វាក្រេស........................................ ៧៤
៣៣. ទួលប្រាសាទក្បាលឡាន........................................ ៧៦
៣៤. ទួលប្រាសាទស្រែតាយ៉ិន........................................ ៧៨
៣៥. ប្រាសាទអូររំដួល........................................ ៨០

**៣៦. ទួលប្រាសាទត្រពាំងបី**.............................................................. ៨២

**សន្និដ្ឋាន**.............................................................................................................. ៨៥

**អនុសាស្ត្រ**............................................................................................................. ៨៨

**បញ្ជីរូបភាព**

រូបលេខ០១៖ កម្មវិធីផ្សព្វផ្សាយវប្បធម៌រៀបចំធ្វើនៅក្នុងការិយាល័យស្រុកត្រពាំងប្រាសាទ ...................... ៧
រូបលេខ០២៖ សកម្មភាពដាក់ផ្លាកសញ្ញាចូលប្រាសាទត្រពាំងប្រាសាទរបស់មន្ត្រីស្រាវជ្រាវ និងប្រជាពលរដ្ឋ ៨
រូបលេខ០៣៖ ប្រាង្គទាំងបីនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង..................................................... ១០
រូបលេខ០៤៖ ផ្តែរពីរផ្ទាំងផ្គុំគ្នា ស្ថិតក្នុងបរិវេណប្រាសាទត្រពាំងប្រាសាទខាងត្បូង................................ ១០
រូបលេខ០៥៖ លិង្គនៅក្នុងបរិវេណប្រាសាទត្រពាំងប្រាសាទខាងត្បូង................................................ ១០
រូបលេខ០៦ និង០៧៖ កូនក្រឡដែលអ្នកស្រុកប្រមូលពីទួលបុរាណនៅជិតប្រាសាទត្រពាំងប្រាសាទខាងត្បូង......... ១១
រូបលេខ០៨៖ ក្លោងទ្វារនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម នៅជ្រុងខាងកើត.............................. ១៤
រូបលេខ០៩៖ ប្រាង្គកណ្តាលនៃប្រាសាទខាងជើងមើលពីទិសខាងកើត សង់ពីថ្មបាយក្រៀម.................. ១៤
រូបលេខ១០៖ ហោត្រៃប្រាសាទត្រពាំងប្រាសាទខាងជើង............................................................... ១៥
រូបលេខ១១៖ ប្រាសាទរលំទឹកខ្មៅ............................................................................................ ១៨
រូបលេខ១២៖ ហោត្រៃនៃប្រាសាទរលំទឹកខ្មៅ............................................................................ ១៨
រូបលេខ១៣៖ តួប្រាសាទខាងជើង និងខឿនប្រាសាទថ្មបាយក្រៀម.................................................. ១៨
រូបលេខ១៤៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទភូមិអូរសោម............................................................. ២០
រូបលេខ១៥ និង១៦៖ ថ្មភក់ និងថ្មបាយក្រៀមដែលជាសំណល់សំណង់គោរពបូជាលើទួលភូមិអូរសោម.. ២០
រូបលេខ១៧៖ បំណែកកុលលាភាជន៍យកពីទួលមនុស្សរស់នៅជិតទួលប្រាសាទអូរសោម...................... ២១
រូបលេខ១៨៖ តួប្រាសាទរលំឆ្កោ............................................................................................. ២២
រូបលេខ១៩ និង២០៖ បំណែកផ្តែរដែលស្ថិតនៅលើទួលប្រាសាទរលំឆ្កោ......................................... ២២
រូបលេខ២១៖ តួប្រាសាទអូចំបក់សង់ពីថ្មបាយក្រៀម.................................................................. ២៤
រូបលេខ២២៖ តួប្រាសាទតាតុញសង់ពីថ្មបាយក្រៀម................................................................... ២៦
រូបលេខ២៣ និង២៤៖ បំណែកហោជាង និងសសរស្តម្ភនៃប្រាសាទតាតុញ....................................... ២៦
រូបលេខ២៥៖ ប្រាង្គទាំបីនៃប្រាសាទល្បើកជ្រៃ............................................................................. ២៨
រូបលេខ២៦៖ ហោត្រៃនៃប្រាសាទល្បើកជ្រៃ............................................................................... ២៨
រូបលេខ២៧៖ កំពែងថ្មបាយក្រៀមខាងត្បូង និងខាងលិច............................................................ ២៨
រូបលេខ២៨៖ ប្រាង្គកណ្តាលនៃប្រាសាទល្បើកជ្រៃ......................................................................... ២៨
រូបលេខ២៩៖ ប្រាង្គខាងជើងនៃប្រាសាទល្បើកជ្រៃ........................................................................ ២៨
រូបលេខ៣០៖ បំណែកបាតក្រឡយកពីទីតាំងក្បែរប្រាសាទល្បើកជ្រៃ................................................ ២៩
រូបលេខ៣១៖ តួប្រាសាទកូនចិន................................................................................................ ៣០
រូបលេខ៣២៖ ក្លោងទ្វារខាងកើតនៃប្រាសាទកូនចិន..................................................................... ៣០
រូបលេខ៣៣៖ កំពែងថ្មបាយក្រៀមនៃប្រាសាទកូនចិន.................................................................. ៣០
រូបលេខ៣៤៖ បំណែកកុលាលភាជន៍យកពីទីទួលក្បែរប្រាសាទកូនចិន.............................................. ៣០
រូបលេខ៣៥៖ តួប្រាសាទ (ទិសខាងកើត)ដែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧........................ ៣២
រូបលេខ៣៦៖ តួប្រាសាទ (ទិសខាងលិច)ដែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧........................ ៣២
រូបលេខ៣៧៖ បំណែកកុលាលភាជន៍យកពីភូមិបុរាណនៅជិតប្រាសាទជិតប្រាសាទកូនចិន.................. ៣៣

រូបលេខ៣៨៖ ក្លោងទ្វារកំពែងទី១នៃប្រាសាទភ្នំសណ្ដក........................................................................ ៣៤
រូបលេខ៣៩៖ ក្លោងទ្វារកំពែងទី២នៃប្រាសាទភ្នំសណ្ដក........................................................................ ៣៤
រូបលេខ៤០៖ សិលាចារឹកចារលើក្លោងទ្វារនៃកំពែងទី២ ដែលមានព្រះនាមរបស់ព្រះបាទសូរ្យវរ្ម័នទី១..... ៣៤
រូបលេខ៤១៖ ផ្ដែរនៃតួប្រាសាទ.................................................................................................. ៣៥
រូបលេខ៤២៖ ផ្ដែរនៅលើក្លោងទ្វារកំពែងទី២.......................................................................... ៣៥
រូបលេខ៤៣៖ បំណែកកុលាលភាជន៍ជាប្រភេទរឹង និងផុយប្រមូលពីទីតាំងភ្នំសណ្ដក......................... ៣៥
រូបលេខ៤៤៖ បំណែកកុលាលភាជន៍ប្រមូលពីទីតាំងភ្នំសណ្ដក..................................................... ៣៥
រូបលេខ៤៥៖ ប្រាង្គប្រាសាទចាក់ច្រែង...................................................................................... ៣៧
រូបលេខ៤៦៖ ផ្ដែរស្ថិតក្នុងបរិវេណប្រាសាទចាក់ច្រែង.............................................................. ៣៧
រូបលេខ៤៧៖ ផ្ដែរមួយទៀតក្នុងបរិវេណប្រាសាទចាក់ច្រែង ត្រូវបំផ្លាញនៅផ្នែកកណ្ដាល.................... ៣៧
រូបលេខ៤៨៖ បំណែកហោជាងមានរូបរាហ៊ូនៅប្រាសាទចាក់ច្រែង.................................................. ៣៨
រូបលេខ៤៩៖ បំណែកផ្ដែរនៃប្រាសាទចាក់ច្រែង......................................................................... ៣៨
រូបលេខ៥០៖ ទួលប្រាសាទភូមិថ្កូវមានកសិណទឹកព័ទ្ធជុំវិញ....................................................... ៣៩
រូបលេខ៥១ និង៥២៖ បំណែកថ្មបាយក្រៀមស្ថិតលើទួលប្រាសាទភូមិថ្កូវ........................................ ៣៩
រូបលេខ៥៣៖ ទីតាំងយកថ្មបាយក្រៀមនៅក្នុងភូមិពានមាស........................................................ ៤១
រូបលេខ៥៤ និង៥៥៖ ទីតាំងយកថ្មបាយក្រៀម នៅភូមិពានមាស................................................... ៤១
រូបលេខ៥៦៖ ទិដ្ឋភាពនៃស្ថានីយយកថ្មភក់ និងទីតាំងសិប្បកម្មថ្មភក់........................................... ៤៣
រូបលេខ៥៧៖ ទីតាំងយកថ្មបាយក្រៀម នៅជើងភ្នំសណ្ដក............................................................ ៤៤
រូបលេខ៥៨៖ ថ្មគោលនៅជិតស្ថានីយយកថ្មបាយក្រៀមក្នុងភូមិពានមាស........................................ ៤៥
រូបលេខ៥៩៖ ថ្មគោលនៅជិតប្រាសាទល្បើកជ្រៃ........................................................................ ៤៧
រូបលេខ៦០៖ ប្រាសាទអូរស្វាយ................................................................................................ ៥១
រូបលេខ៦១ និង៦២៖ ផ្ដែរ និងសន្លឹករកានៅក្នុងបរិវេណប្រាសាទអូរស្វាយ...................................... ៥១
រូបលេខ៦៣៖ ទួលប្រាសាទទំនប់អភិវឌ្ឍមានផ្ដែរយកពីតំបន់ផ្សេង................................................. ៥១
រូបលេខ៦៤ និង៦៥៖ តួប្រាសាទដែលសង់ពីថ្មភក់ ដើមឈើរលំលើ និងរុក្ខជាតិផ្សេងៗដុះស៊ុបទ្រុបពីលើ.. ៥៤
រូបលេខ៦៦៖ ថ្មគោលធ្វើពីថ្មភក់ ក្នុងភូមិទួលគ្រួស..................................................................... ៥៦
រូបលេខ៦៧៖ បំណែកកុលាលភាជន៍ប្រមូលពីស្ថានីយក្នុងភូមិថ្នល់កែង ឃុំផ្អាវ................................. ៥៨
រូបលេខ៦៨៖ ទួលប្រាសាទចារ.................................................................................................. ៦១
រូបលេខ៦៩៖ សំណល់មេទ្វារប្រាសាទដែលមានអក្សរចារឹកលើមេទ្វារនោះ....................................... ៦១
រូបលេខ៧០៖ សំណល់តួប្រាសាទ.............................................................................................. ៦១
រូបលេខ៧១៖ តួប្រាសាទទំនប់ដាច់សង់អំពីឥដ្ឋ........................................................................ ៦៣
រូបលេខ៧២៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទត្រពាំងពោធិ៍............................................................ ៦៥
រូបលេខ៧៣៖ ទម្របដិមា ឬអាចជាទម្រលិង្គ................................................................................ ៦៥
រូបលេខ៧៤៖ ដុំថ្មបាយក្រៀម និងថ្មភក់ដែលជាសមាសធាតុ នៃសំណង់ប្រាសាទស្ថិតលើទួលត្រពាំងពោធិ៍ ៦៥
រូបលេខ៧៥៖ តួប្រាសាទក្រហម.................................................................................................. ៦៨
រូបលេខ៧៦៖ តួប្រាសាទក្រហម មើលពីទិសខាងកើត.................................................................. ៦៨
រូបលេខ៧៧៖ សសរស្ដម្ភដួលនៅមុខតួប្រាសាទក្រហម.................................................................. ៦៨

រូបលេខ៧៨៖ ទួលប្រាសាទត្រាំចាន...................................................................................... ៧០
រូបលេខ៧៩៖ ទម្រូបដិមានៅលើទួលត្រាំចាន.......................................................................... ៧០
រូបលេខ៨០៖ ដុំថ្មបាយក្រៀមដែលជាសមាសជាតុសំណង់ប្រាសាទនៅលើទួលត្រាំចាន...................... ៧០
រូបលេខ៨១៖ តួប្រាសាទត្រពាំងទឹម........................................................................................ ៧២
រូបលេខ៨២៖ ក្លោងទ្វារខាងកើតប្រាសាទត្រពាំងទឹម.................................................................. ៧២
រូបលេខ៨៣៖ កំពែងនៃប្រាសាទត្រពាំងទឹមសង់ពីថ្មបាយក្រៀម.................................................... ៧២
រូបលេខ៨៤៖ តួប្រាសាទស្វាក្រេស......................................................................................... ៧៤
រូបលេខ៨៥៖ ផ្តែរប្រាសាទស្វាក្រេស នៅលើដីពីមុខតួប្រាសាទ........................................................ ៧៤
រូបលេខ៨៦៖ ថ្មភក់រាងមូលប្រហែលជាដំបូលប្រាសាទ.............................................................. ៧៤
រូបលេខ៨៧៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទក្បាលឡាន................................................................ ៧៦
រូបលេខ៨៨ និង៨៩៖ បំណែកថ្មភក់ដែលជាទម្រូបដិមា និងដុំថ្មបាយក្រៀមដែលជាសមាសជាតុនៃសំណង់ប្រាសាទ ៧៦
រូបលេខ៩០៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទស្រែតាយ៉ិន................................................................ ៧៨
រូបលេខ៩១៖ តួប្រាសាទអូរវំដួល សង់ពីឥដ្ឋ និងមេទ្វារសង់ពីថ្មភក់.................................................. ៨០
រូបលេខ៩២៖ ផ្នែកខាងក្នុងនៃតួប្រាសាទអូរវំដួល........................................................................ ៨០
រូបលេខ៩៣៖ ថ្មភក់នៅរាយប៉ាយក្បែរតួប្រាសាទអូរវំដួល............................................................. ៨០
រូបលេខ៩៤៖ ទិដ្ឋភាពនៃទួលប្រាសាទត្រពាំងបី ដែលមានខ្ទមអ្នកតាមួយ......................................... ៨២
រូបលេខ៩៥, ៩៦និង៩៧៖ វត្ថុបុរាណរក្សាទុកក្នុងខ្ទមអ្នកតា ទុកជាគ្រឿងសក្ការៈ................................ ៨២

## បញ្ជីផែនទី និងប្លង់ប្រាសាទ


ផែនទីលេខ១៖ ផែនទីរដ្ឋបាលស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ........................................... ៤
ផែនទីលេខ២៖ ទីតាំងប្លង់ស្រុកត្រពាំងប្រាសាទ.............................................................................. ៦
ផែនទីលេខ៣៖ ប្លង់បាតប្រាសាទត្រពាំងប្រាសាទខាងត្បូង................................................................. ៩
ផែនទីលេខ៤៖ ផែនទីបង្ហាញទីតាំងប្រាសាទខាងត្បូងស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ... ១២
ផែនទីលេខ៤៖ ប្លង់ទូទៅនៃប្រាសាទត្រពាំងប្រាសាទខាងជើង............................................................ ១៣
ផែនទីលេខ៥៖ ប្លង់បាតនៃប្រាសាទត្រពាំងប្រាសាទខាងជើង............................................................. ១៥
ផែនទីលេខ៦៖ ប្លង់មន្ទីរពេទ្យនៃប្រាសាទសំរោង.............................................................................. ១៦
ផែនទីលេខ៧៖ ផែនទីបង្ហាញទីតាំងប្រាសាទខាងជើងស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ.. ១៧
ផែនទីលេខ៨៖ ផែនទីបង្ហាញទីតាំងប្រាសាទរលំទឹកខ្មៅស្ថិតនៅឃុំត្រពាំងប្រាសាទ ............................ ១៩
ផែនទីលេខ៩៖ ផែនទីបង្ហាញទីតាំងគ្រឹះប្រាសាទអូរសោមខ្មៅស្ថិតនៅឃុំត្រពាំងប្រាសាទ ..................... ២១
ផែនទីលេខ១០៖ ផែនទីបង្ហាញទីតាំងប្រាសាទរលំឆ្កោស្ថិតនៅឃុំត្រពាំងប្រាសាទ ............................... ២៣
ផែនទីលេខ១១៖ ផែនទីបង្ហាញទីតាំងប្រាសាទអូរចំបក់ ស្ថិតនៅឃុំត្រពាំងប្រាសាទ ........................... ២៥
ផែនទីលេខ១២៖ ផែនទីបង្ហាញទីតាំងប្រាសាទតាគុញស្ថិតនៅឃុំត្រពាំងប្រាសាទ .............................. ២៧
ផែនទីលេខ១៣៖ ផែនទីបង្ហាញទីតាំងប្រាសាទល្បើកជ្រៃស្ថិតនៅឃុំត្រពាំងប្រាសាទ .......................... ២៩
ផែនទីលេខ១៤៖ ផែនទីបង្ហាញទីតាំងប្រាសាទកូនចិនស្ថិតនៅឃុំត្រពាំងប្រាសាទ .............................. ៣១
ផែនទីលេខ១៥៖ ផែនទីបង្ហាញទីតាំងប្រាសាទជ័យវរ្ម័នទី៧ស្ថិតនៅឃុំត្រពាំងប្រាសាទ ....................... ៣៣
ផែនទីលេខ១៦៖ ផែនទីបង្ហាញទីតាំងប្រាសាទភ្នំសណ្ដកខ្មៅស្ថិតនៅឃុំត្រពាំងប្រាសាទ ...................... ៣៦
ផែនទីលេខ១៧៖ ផែនទីបង្ហាញទីតាំងប្រាសាទចាក់ច្រែងស្ថិតនៅឃុំត្រពាំងប្រាសាទ .......................... ៣៨
ផែនទីលេខ១៨៖ ផែនទីបង្ហាញទីតាំងប្រាសាទភូមិថ្កូវស្ថិតនៅឃុំត្រពាំងប្រាសាទ ............................... ៤០
ផែនទីលេខ១៩៖ ផែនទីបង្ហាញទីតាំងស្ថានីយយកថ្មបាយក្រៀមស្ថិតនៅឃុំត្រពាំងប្រាសាទ ................. ៤២
ផែនទីលេខ២០៖ ផែនទីបង្ហាញទីតាំងស្ថានីយយកថ្មភក់ស្ថិតនៅឃុំត្រពាំងប្រាសាទ ........................... ៤៣
ផែនទីលេខ២១៖ ផែនទីបង្ហាញទីតាំងស្ថានីយយកថ្មបាយក្រៀមនៅភ្នំសណ្ដកស្ថិតនៅឃុំត្រពាំងប្រាសាទ.. ៤៤
ផែនទីលេខ២២៖ ផែនទីបង្ហាញទីតាំងថ្មគោលនៅជិតស្ថានីយយកថ្មបាយក្រោមស្ថិតនៅឃុំត្រពាំងប្រាសាទ............ ៤៦
ផែនទីលេខ២៣៖ ផែនទីបង្ហាញទីតាំងថ្មគោលនៅជិតប្រាសាទល្បើកជ្រៃស្ថិតនៅឃុំត្រពាំងប្រាសាទ ....... ៤៨
ផែនទីលេខ២៤៖ ផែនទីបង្ហាញទីតាំងប្រាសាទ និងស្ថានីយបុរាណស្ថិតនៅឃុំត្រពាំងប្រាសាទ .............. ៥០
ផែនទីលេខ២៥៖ ផែនទីបង្ហាញទីតាំងប្រាសាទអូរស្វាយស្ថិតនៅឃុំអូរស្វាយ ...................................... ៥២
ផែនទីលេខ២៦៖ ផែនទីបង្ហាញទីតាំងប្រាសាទត្រពាំងបីស្ថិតនៅឃុំអូរស្វាយ ...................................... ៥៣
ផែនទីលេខ២៧៖ ផែនទីបង្ហាញទីតាំងទួលប្រាសាទទំនប់អភិវឌ្ឍស្ថិតនៅឃុំអូរស្វាយ .......................... ៥៤
ផែនទីលេខ២៨៖ ផែនទីបង្ហាញទីតាំងប្រាសាទទួលគ្រួសស្ថិតនៅឃុំអូរស្វាយ .................................... ៥៥
ផែនទីលេខ២៩៖ ផែនទីបង្ហាញទីតាំងថ្មគោលក្នុងភូមិទួលគ្រួសស្ថិតនៅឃុំអូរស្វាយ .......................... ៥៦
ផែនទីលេខ៣០៖ ផែនទីបង្ហាញទីតាំងប្រាសាទ និងស្ថានីយបុរាណស្ថិតនៅឃុំអូរស្វាយ ....................... ៥៧
ផែនទីលេខ៣១៖ ផែនទីបង្ហាញទីតាំងភូមិបុរាណ ត្រពាំងបុរាណស្ថិតនៅឃុំផ្អាវ ................................. ៥៩
ផែនទីលេខ៣២៖ ផែនទីបង្ហាញទីតាំងទួលប្រសើរស្ថិតនៅឃុំបាក់អន្លូង ........................................... ៦០

ផែនទីលេខ៣៣៖ ផែនទីបង្ហាញទីតាំងប្រាសាទចារស្ថិតនៅឃុំទំនប់ដាច់ ........................................ ៦២
ផែនទីលេខ៣៤៖ ផែនទីបង្ហាញទីតាំងប្រាសាទទំនប់ដាច់ស្ថិតនៅឃុំទំនប់ដាច់ ................................ ៦៤
ផែនទីលេខ៣៥៖ ផែនទីបង្ហាញទីតាំងទួលត្រពាំងពោធិ៍ស្ថិតនៅឃុំទំនប់ដាច់ .................................... ៦៦
ផែនទីលេខ៣៦៖ ផែនទីបង្ហាញទីតាំងប្រាសាទ និងស្ថានីយបុរាណស្ថិតនៅឃុំទំនប់ដាច់ ...................... ៦៧
ផែនទីលេខ៣៧៖ ផែនទីបង្ហាញទីតាំងប្រាសាទក្រហមស្ថិតនៅឃុំព្រះប្រឡាយ ................................. ៦៩
ផែនទីលេខ៣៨៖ ផែនទីបង្ហាញទីតាំងទួលត្រាំចានស្ថិតនៅឃុំព្រះប្រឡាយ ...................................... ៧១
ផែនទីលេខ៣៩៖ ផែនទីបង្ហាញទីតាំងប្រាសាទត្រពាំងទឹមស្ថិតនៅឃុំព្រះប្រឡាយ ............................ ៧៣
ផែនទីលេខ៤០៖ ផែនទីបង្ហាញទីតាំងប្រាសាទស្វាក្រេសស្ថិតនៅឃុំព្រះប្រឡាយ ............................... ៧៥
ផែនទីលេខ៤១៖ ផែនទីបង្ហាញទីតាំងទួលប្រាសាទក្បាលឡានស្ថិតនៅឃុំព្រះប្រឡាយ ....................... ៧៧
ផែនទីលេខ៤២៖ ផែនទីបង្ហាញទីតាំងទួលប្រាសាទស្រែតាឃិនស្ថិតនៅឃុំព្រះប្រឡាយ ....................... ៧៩
ផែនទីលេខ៤៣៖ ផែនទីបង្ហាញទីតាំងប្រាសាទភូមិអូររំដួលស្ថិតនៅឃុំព្រះប្រឡាយ ............................ ៨១
ផែនទីលេខ៤៥៖ ផែនទីបង្ហាញទីតាំងទួលប្រាសាទត្រពាំងបីស្ថិតនៅឃុំអូរស្វាយ ............................... ៨៣
ផែនទីលេខ៤៤៖ ផែនទីបង្ហាញទីតាំងប្រាសាទ និងស្ថានីយបុរាណក្នុងស្រុកត្រពាំងប្រាសាទ ................ ៨៤

# I. សេចក្តីផ្តើម

ការសិក្សាស្រាវជ្រាវអំពីប្រាសាទបុរាណខ្មែរ បានចាប់ផ្តើមផុលផុសនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ដោយមានអ្នកប្រាជ្ញជនជាតិបារាំងមួយចំនួនបានធ្វើការសិក្សាចុះបញ្ជីឈ្មោះប្រាសាទទូទាំងប្រទេសកម្ពុជា រួមមានលោក E. Lunet De Lajonquier លោក Etien Aymonier និងលោក Bernard Phillipes Grosllier ជាដើម។ ស្នាដៃស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំងទាំងបីគឺជាមូលដ្ឋានគ្រឹះយ៉ាងចម្បង សម្រាប់ការសិក្សាពីប្រាសាទបុរាណខ្មែររបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ។ ក្រោយមកការសិក្សាស្រាវជ្រាវពី បុរាណវត្ថុវិទ្យាបានរាំងស្ទះដំណើរ ដោយសារប្រទេសត្រូវប្រឈមនឹងសង្គ្រាមស៊ីវិល, របបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ និងបន្តដោយសង្គ្រាមរាំរ៉ៃអូសបន្លាយអស់ច្រើនឆ្នាំ។ ក្រោយពីទទួលបានសន្តិភាព និងសន្តិសុខ ប្រទេសកម្ពុជាក៏ចាប់ផ្តើមធ្វើដំណើរឈានចូលដល់ដំណាក់កាលនៃការវិវត្តន៍លើគ្រប់វិស័យ ពិសេសវិស័យអប់រំ និងការស្រាវជ្រាវដែលកំពុងដំណើរការយ៉ាងសកម្ម។ ស្ថាប័នជាតិ និងអន្តរជាតិបានចាប់អារម្មណ៍ខ្លាំងលើការងារសិក្សាស្រាវជ្រាវលើតំបន់ប្រវត្តិសាស្ត្រជាច្រើនក្នុងប្រទេសកម្ពុជាមានដូចជាៈ តំបន់អង្គរ តំបន់សម្បូណ៍ព្រៃគុក តំបន់អង្គរបុរី និងតំបន់ដ៏ទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្ថាប័នជាតិ និងអន្តរជាតិបានសហការណ៍យ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ បង្កើតយុទ្ធនាការការពារបេតិកភណ្ឌជាតិ ដូចជាទប់ស្កាត់អំពើរចោរកម្មវត្ថុបុរាណពីស្រុកខ្មែរយកទៅលក់នៅបរទេស ការបំផ្លាញរមណីយដ្ឋានប្រវត្តិសាស្ត្រ ការពារទប់ស្កាត់ការបំផ្លាញពីធម្មជាតិនិងជួសជុលប្រាសាទមួយចំនួន។

ជាក់ស្តែង នាពេលថ្មីៗកន្លងមកនេះ មន្ត្រីជំនាញបុរាណវត្ថុវិទ្យានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមសហការណ៍ជាមួយស្ថាប័នអន្តរជាតិមួយចំនួន បានសិក្សានិងចុះបញ្ជីប្រាសាទ និងស្ថានីយបុរាណក្នុងបញ្ជីបេតិកភណ្ឌជាតិនៅទូទាំងប្រទេស ដោយរកឃើញប្រាសាទ និងស្ថានីយបុរាណជាង៤០០០។ ទោះជាយ៉ាងនេះក្តី នៅមានប្រាសាទមួយចំនួនពុំទាន់បានចុះបញ្ជីនៅឡើយ ដោយសារប្រាសាទទាំងនោះស្ថិតក្នុងព្រៃជ្រៅអ្នកស្រាវជ្រាវមិនអាចចូលដល់ ជាពិសេសប្រាសាទដែលស្ថិតក្នុងតំបន់ព្រៃក្រាស់ នៅតាមជួរភ្នំដងរែកជាដើម។ បណ្តាខេត្តដែលនៅជាប់ជើងភ្នំដងរែកមានដូចជា ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ ការសិក្សាស្រាវជ្រាវពីបុរាណវត្ថុវិទ្យានៅមានកម្រិត ដោយហេតុថាតំបន់នេះ គឺជាទីតាំងឈរជើងរបស់កងទ័ពខ្មែរក្រហម ដែលជាញឹកញយមានការប្រយុទ្ធគ្នាជាមួយកងទ័ពខាងរដ្ឋកម្ពុជា។ ស្រុកបីក្នុងចំណោមស្រុកទាំង៥របស់ខេត្តឧត្តរមានជ័យដែលមានការសិក្សាស្រាវជ្រាវច្រើននោះគឺ ស្រុកចុងកាល់ ស្រុកសំរោង និងស្រុកបន្ទាយអំពិល។ ដោយឡែកស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ការសិក្សាអំពីប្រាសាទគឺមានតិចតួចប៉ុណ្ណោះ។ ជាក់ស្តែង មានប្រាសាទត្រពាំងប្រាសាទតែមួយគត់ក្នុងស្រុកត្រពាំងប្រាសាទដែលបានចុះក្នុងបញ្ជីទិន្នន័យដែលក្រសួងវប្បធម៌វិចិត្រសិល្បៈបានសិក្សាស្រាវជ្រាវ។

ត្រពាំងប្រាសាទ គឺជាស្រុកមួយស្ថិតក្នុងទឹកដីនៃខេត្តឧត្តរមានជ័យ ដែលសំបូរទៅដោយព្រៃឈើ តាមបណ្តោយជាប់ជួរភ្នំដងរែក ដែលមានព្រំប្រទល់ខាងត្បូងជាប់ខេត្តសៀមរាប ខាងកើតជាប់ខេត្តព្រះវិហារ ខាងជើងជាប់ព្រំដែនប្រទេសសៀម និងខាងលិចជាប់ស្រុកអន្លង់វែងនៃខេត្តឧត្តរមានជ័យ និងមានផ្ទៃដីសរុប៣២៦៥២ ហិចតា (Trapeang Prasat Data Book, 2009)។ ទីតាំងភូមិសាស្ត្រតំបន់នេះ មិនមានការតាំងទីលំនៅរបស់ប្រជាជនច្រើនដូចនៅតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជាទេ។ បច្ចុប្បន្ននេះ ស្រុកត្រពាំងប្រាសាទមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់។ ថ្នល់ចាក់កៅស៊ូមួយខ្សែដែលភ្ជាប់ពីស្រុកបាគង ខេត្តសៀមរាបមកស្រុកអន្លង់វែង និងបន្តពីស្រុកអន្លង់វែងមកស្រុកត្រពាំងប្រាសាទ កសាងរួចរាល់ហើយ។ ជាងនេះទៀត មាន

ផ្លូវកៅស៊ូមួយខ្សែចំងាយប្រមាណជាង៣៣គីឡូម៉ែត្រ ពីស្រុកត្រពាំងប្រាសាទទៅប្រាសាទព្រះវិហារក៏បានកសាងរួចរាល់ផងដែរ។ កំណើនប្រជាជនកំពុងកើនឡើងដោយសារស្ថានការរបស់ស្រុកកំពុងស្ថិតក្នុងលក្ខខណ្ឌសមប្រកប ប្រជាជនអាចរស់នៅ និងប្រកបមុខរបរចិញ្ចឹមជីវិតបាន។

ក្រៅពីធនធានធម្មជាតិ ដូចជាព្រៃឈើ សត្វព្រៃ និងរ៉ែត្បូងថ្ម ទឹកដីនៃស្រុកត្រពាំងប្រាសាទ បន្សល់ទុកកេរដំណែលបុរាណជាច្រើន គឺប្រាសាទ និងស្ថានីយបុរាណមួយចំនួនទៀត ដែលអ្នកស្រាវជ្រាវភាគច្រើនមិនសូវចាប់អារម្មណ៍ និងធ្វើការសិក្សាស្រាវជ្រាវនៅឡើយទេ។

ដោយមើលឃើញពីសក្តានុពលនៃការស្រាវជ្រាវនៅតំបន់ស្រុកត្រពាំងប្រាសាទ មន្ត្រីផ្នែកបុរាណវត្ថុវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំផែនសិក្សាស្រាវជ្រាវ និងរុករកកេរដំណែលបេតិកភណ្ឌទាំងអស់នោះ ព្រមទាំងធ្វើផែនទីសារពើភណ្ឌ។ បន្ទាប់ពីទទួលបានការគាំទ្រថវិកាពីរាជបណ្ឌិត្យសភាកម្ពុជា មន្ត្រីជំនាញផ្នែកបុរាណវត្ថុវិទ្យានៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ក៏បានចុះសិក្សាស្រាវជ្រាវ ស្វែងរកស្ថានីយបុរាណ ប្រាសាទក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងបានទទួលលទ្ធផល ដូចរៀបរាប់នៅខាងក្រោម។

- **គោលបំណងនិងអត្ថប្រយោជន៍នៃគម្រោង**

គោលបំណងនៃការសិក្សាមាន៖

១-ធ្វើផែនទីស្ថានីយបុរាណវត្ថុវិទ្យាសម្រាប់ស្រុកត្រពាំងប្រាសាទ។ ផែនទីនេះជាជំនួយមួយដល់ការកំណត់បរិវេណប្រាសាទ ក៏ដូចជាការបង្ហាញទីតាំងស្ថានីយ និងបរិបទជុំវិញ។ មានផែនទីស្ថានីយ បុរាណវត្ថុវិទ្យាស្រុកត្រពាំងប្រាសាទ យើងងាយស្រួលដល់ការរៀបផែនការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងស្រុក នៅថ្ងៃអនាគត។

២-សិក្សាពីប្រាសាទនិងស្ថានីយទាំងអស់ដើម្បីសិក្សាស្វែងយល់ពីអាយុកាល, រចនាបថ បច្ចេកទេសនៃការសាងសង់។

៣-សិក្សាប្រៀបធៀបប្រាសាទឬស្ថានីយទាំងនោះទៅនឹងប្រាសាទនៅតំបន់អង្គរ ដែលមានអាយុកាលនិងរចនាបថច្បាស់លាស់។

៤-ថតរូបទុកជាឯកសារកំណត់ត្រាពីស្ថានភាពទូទៅនៃប្រាសាទឬស្ថានីយ។ រូបថតជាឯកសារមួយប្រភេទដែលអាចថតទុកនូវស្ថានភាពផ្សេងៗដូចជាការបែកបាក់ និងស្ថានភាពនៅល្អស្អាតរបស់ប្រាសាទ។

៥-ផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងផែនទីស្ថានីយបុរាណវត្ថុវិទ្យាដែលបានធ្វើរួចដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅក្បែរប្រាសាទឬស្ថានីយឱ្យបានដឹងពីវត្តមាននៃបេតិកភណ្ឌទាំងអស់នោះ ដើម្បីបំផុសគំនិតឱ្យចេះស្រឡាញ់ និងចូលរួមថែរក្សា ឬអភិរក្សទ្រព្យសម្បត្តិមានក្នុងទឹកដីរបស់ពួកគេ ឱ្យគង់វង្ស។

៦-រៀបចំស្ថានីយបុរាណវិទ្យា ដោយធ្វើការសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ រួមជាមួយអាជ្ញាធរដែនដីចាប់ពីថ្នាក់ខេត្ត, ស្រុក, ឃុំ, និងភូមិ ដើម្បីកំណត់បរិវេណប្រាសាទឬស្ថានីយ ជៀសវាងការរំខាន ឬបំផ្លាញប្រាសាទឬស្ថានីយដោយប្រការណាមួយ។

៧-លទ្ធផលស្រាវជ្រាវជាចំណែកមួយក្នុងការចូលរួមអភិវឌ្ឍទេសចរណ៍ ដោយប្រែក្លាយតំបន់ស្រុកត្រពាំងប្រាសាទ ជារមនីយដ្ឋានទេសចរណ៍វប្បធម៌សម្រាប់ប្រជាជនក្នុងតំបន់ទេសចរជាតិ និងអន្តរជាតិ និងក៏ជាចំណែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍនៅតំបន់ដាច់ស្រយាល និងនៅតាមព្រំដែន។

**វិធីសាស្ត្រស្រាវជ្រាវ**

ដើម្បីសិក្សាគម្រោងនេះឱ្យបានជោគជ័យដូច ដែលមានចែងក្នុងគោលបំណងខាងលើ វិធីសាស្ត្រសិក្សាស្រាវជ្រាវមួយចំនួនបានជ្រើសរើសក្នុងការប្រតិបត្តិគម្រោងនេះ។

ក-សិក្សាឯកសារដែលអ្នកសិក្សាស្រាវជ្រាវមុនៗបានធ្លាប់សិក្សា ជាពិសេសសិក្សាឯកសារអ្នកប្រាជ្ញសាសន៍បារាំងដែលបានសិក្សានិងចុះបញ្ជីប្រាសាទនៅទូទាំងប្រទេសកម្ពុជា។

ខ-សិក្សាលើផែនទីដែលផលិតនៅឆ្នាំ១៩៥៤របស់អាមេរិក មុនពេលអាមេរិកចាប់ផ្តើមវាយលុកឥទ្ធិពលរបស់ខ្លួនចូលក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងផែនទីនេះ មានបង្ហាញពីឈ្មោះភូមិដែលជាស្ថាននាម ឬស្ថានីយបុរាណ ព្រមទាំងមានបង្ហាញពីទីតាំងដែលមានប្រាសាទឬក៏ត្រពាំងធំៗថែមទៀត។

គ-ធ្វើសម្ភាសន៍យកទិន្នន័យព័ត៌មានស្តីពីទីតាំងប្រាសាទ ឬស្ថានីយបុរាណវត្ថុវិទ្យាក្នុងទូទាំងស្រុកត្រពាំងប្រាសាទ ពីប្រធានឃុំរបស់ស្រុកត្រពាំងប្រាសាទ។ ដើម្បីជួយសម្រួលដំណើរការស្រាវជ្រាវនេះឱ្យបានលឿន និងជាប្រយោជន៍នៃការផ្សព្វផ្សាយពីបេតិកភណ្ឌប្រាសាទបុរាណ និងស្ថានីយបុរាណ យើងនឹងរៀបចំជាកម្មវិធី ឬវគ្គផ្សព្វផ្សាយតូចមួយ ដោយអញ្ជើញមេឃុំទាំងអស់ឱ្យចូលរួម។ ឆ្លៀតឱកាសនោះ យើងបានធ្វើសម្ភាសន៍ជាមួយពួកគាត់ដើម្បីទទួលព័ត៌មានពីវត្តមានរបស់ប្រាសាទ និងស្ថានីយបុរាណក្នុងឃុំ របស់ពួកគាត់។

ឃ-បន្ទាប់ពីសិក្សាឯកសារ, សិក្សាពីផែនទី និងសម្ភាសន៍ជាមួយមេឃុំរួចមក យើងនឹងចាប់ផ្តើមចុះសិក្សាដល់ទីតាំងប្រាសាទ និងស្ថានីយបុរាណ។ ដំណាក់កាលនេះគឺជាយុទ្ធនាការណ៍រុករកប្រាសាទ និងស្ថានីយបុរាណក្នុងស្រុកត្រពាំងប្រាសាទ។

ង-ផ្សព្វផ្សាយពីលទ្ធផលនិងការកំណត់ព្រំដែនរបស់ប្រាសាទដល់ប្រជាជនក្នុងតំបន់ឱ្យយល់ និងបញ្ឈប់នូវរាល់សកម្មភាពទាំងឡាយទោះដោយចេតនា ឬអចេតនាដែលអាចប៉ះពាល់ទៅដល់ប្រាសាទ និងបរិវេណប្រាសាទដែលបានកំណត់។

ច-ធ្វើសហប្រតិបត្តិការណ៍ជាមួយមន្ត្រីអាជ្ញាធរដែនដី គឺសុំស្នើលោក ផុន ជាកុសល ជាអភិបាលរងស្រុកត្រពាំងប្រាសាទ ឱ្យចូលរួមក្នុងដំណើរប្រព្រឹត្តទៅនៃការចុះសិក្សាដល់ទីកន្លែង។ ជាងនេះទៀត លោក ផុន ជាកុសល ជាអតីតនិស្សិតនៃមហាវិទ្យាល័យបុរាណវិទ្យា យល់ដឹងពីការសិក្សាស្រាវជ្រាវលើវិស័យនេះ ហើយលោកស្គាល់ពីទីតាំងស្ថានីយក្នុងស្រុកត្រពាំងប្រាសាទជាច្រើន។

## ផែនទីរដ្ឋបាលស្រុកត្រពាំងប្រាសាទខេត្តឧត្តរមានជ័យ



## II-ប្រវត្តស្រុកត្រពាំងប្រាសាទ

ស្រុកត្រពាំងប្រាសាទជាស្រុកមួយក្នុងចំណោមស្រុកទាំងបួន និងក្រុងមួយរបស់ខេត្តឧត្តរមានជ័យ ក្នុងនោះមាន ក្រុងសំរោង, ស្រុកចុងកាល់, ស្រុកបន្ទាយអំពិល, ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ។ ភូមិសាស្ត្ររដ្ឋបាលរបស់ស្រុកត្រពាំងប្រាសាទ ភាគខាងជើងទល់នឹងព្រំប្រទល់ប្រទេសថៃ តាមបណ្តោយជួរភ្នំដងរែកប្រវែងជាង៤០គីឡូម៉ែត្រ។ ភាគខាងកើតទល់នឹងស្រុកជាំក្សានខេត្តព្រះវិហារ។ ភាគខាងលិចទល់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យត្រង់ចំណុចខ្សែស្របលេខ១០ និងភាគខាងត្បូងទល់នឹងស្រុកស្វាយលើ ខេត្តសៀមរាប។ ទីតាំងសាលាស្រុកស្ថិតនៅក្នុងឃុំត្រពាំងប្រាសាទ។ ស្រុកត្រពាំងប្រាសាទមានឃុំចំណុះចំនួន៦ ភូមិចំនួន៣៨ និងមានភូមិចំណុះចំនួន១២ភូមិទៀត។ ក្រៅពីប្រជាជនមូលដ្ឋានក៏មានប្រជាជនធ្វើចំណាកស្រុកហូរចូលមករស់នៅក្នុងភូមិ ឃុំ ទូទាំងស្រុក ចាប់តាំងពីស្រុកបានបង្កើតឡើងរហូតមកទល់បច្ចុប្បន្ន មានចំនួន៨២៤២គ្រួសារ មនុស្សចំនួន ៣៧៥៤៤នាក់ ស្រី១៨៦២១នាក់។

ស្រុកត្រពាំងប្រាសាទទើបបង្កើតថ្មី តាមអនុក្រិត្យលេខ២៣ អនក្របក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្រោយពេលប្រទេសកម្ពុជាបានទទួលសន្តិភាពពេញលេញ។ អភិបាលស្រុកដែលបានតែងតាំងក្នុងឆ្នាំនោះដែរគឺលោកជុំ ជាតិ។ ក្រោយពីលោក ជុំ ជាតិ បានតែងជាអភិបាលស្រុកនៅរង្វង់ឆ្នាំ១៩៩៨-៩៩ លោកបានរៀបចំស្រុកនេះឲ្យមានហេដ្ឋារចនាសម្ព័ន្ធដូចស្រុកនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

កាលដើមឡើយ គឺរហូតដល់សម័យលន់ នល់ នៅពេលប្រទេសកម្ពុជាពុំទាន់មានសង្គ្រាមផ្ទៃក្នុង ពេលនោះពុំទាន់មានឈ្មោះស្រុកត្រពាំងប្រាសាទនៅឡើយទេ។ ទឹកដីស្រុកត្រពាំងប្រាសាទបច្ចុប្បន្នគឺជាទឹកដីរបស់ស្រុកអង្គរជុំ ខេត្តសៀមរាប និងខ្លះជាទឹកដីនៃស្រុកជាំក្សាន ខេត្តព្រះវិហារ។ មានន័យថា ព្រំប្រទល់រវាងស្រុកអង្គរជុំ និងស្រុកជុំក្សាន គឺនៅត្រង់ច្រកព្រះប្រឡាយ។

ដោយសារតំបន់ស្រុកនេះមានប្រាសាទមួយ និងមានត្រពាំងធំ អតីតលោកអភិបាលស្រុក ជុំ ជាតិ ក៏សម្រេចដាក់ឈ្មោះស្រុកថា "ស្រុកត្រពាំងប្រាសាទ"។ ចំណែកឈ្មោះឃុំមួយចំនួនគឺយកតាមឈ្មោះភូមិដែលមានស្រាប់។ ឧទាហរណ៍ ឃុំបាក់អន្លូងគឺជាឈ្មោះរបស់ភូមិបាក់អន្លូង ដោយយកទីតាំងភូមិប្រែក្លាយជាទីតាំងឃុំវិញ។ ដូចគ្នានេះដែរ ឃុំព្រះប្រឡាយជាភូមិចាស់។ ប្រជាជនហៅថា "ប្រឡាយ" មកពីនៅទីនោះ ភ្នំដងរែកមានជម្រាលទាប មើលទៅដូចជាប្រឡាយដែលអាចឲ្យមនុស្សឆ្លងកាត់ធ្វើដំណើរទៅកាន់ប្រទេសថៃឡង់ដ៍បាន។ ដូច្នេះហើយ ទើបគេហៅថាព្រះប្រឡាយរហូតដល់បច្ចុប្បន្ន។ ចំណែកឃុំទំនប់ដាច់ជាឃុំថ្មីទើបបង្កើត ដោយសារមានទំនប់មួយសង់នៅក្នុងទីតាំងនោះ។

មុននឹងសម្រេចជ្រើសរើសទីតាំងស្រុកបច្ចុប្បន្ន ថ្នាក់ដឹកនាំស្រុកនៅពេលនោះ បានពិភាក្សាគ្នាជ្រើសរើសទីតាំងនៃស្រុក។ កាលនោះ មានទីតាំងពីរ គឺទីតាំងស្រុកបច្ចុប្បន្ន និងនៅទំនប់ដាច់ ព្រោះមានមនុស្សរស់នៅច្រើនស្រាប់ ក៏ប៉ុន្តែស្ថិតនៅជិតព្រំដែនពេក។ បញ្ហានេះហើយ ដែលមិនអាចជ្រើសរើសយកទីតាំងស្រុកនៅទំនប់ដាច់បាន។ ទីបញ្ចប់ ថ្នាក់ដឹកនាំស្រុកក៏បានសម្រេចចិត្តយកទីតាំងស្រុកនៅទីតាំងបច្ចុប្បន្ន។

នៅមុនឆ្នាំ១៩៩៨ ទីរួមស្រុកត្រពាំងប្រាសាទគឺជាសុទ្ធតែជាព្រៃ មានដើមឈើធំៗដុះ គ្មានផ្ទះសម្បែងមួយឡើយ។ បន្តិចម្តងៗ លោកអតីតអភិបាលស្រុក ជុំ ជាតិ បានកសាងផ្លូវ ភ្ជាប់ត្រង់ពីអន្លង់វែងមកទីរួមស្រុក និងរៀបចំផ្លូវខ្វាត់ខ្វែងក្នុងទីរួមស្រុក។ ផ្លូវដែលបានកសាងក្នុងទីរួមស្រុកមានទំហំធំល្អ។ សាលាស្រុកក៏បានសាងសង់។ នៅក្នុងប្លង់រៀបចំដែនដីរបស់លោកអតីតអភិបាលស្រុក ជុំ ជាតិ គឺមានការិយាល័យរដ្ឋបាលផ្សេងៗ នៅ

ក្បែរៗសាលាស្រុក, មានផ្សារ, លំនៅដ្ឋាន, និងមានសួនច្បារសម្រាប់ប្រជាជនកំសាន្ត និងបន្ធូរអារម្មណ៍។ អ្វីដែលគួរឲ្យចាប់អារម្មណ៍គឺ ទំហំនៃផ្លូវក្នុងទីរួមស្រុកត្រពាំងប្រាសាទទាំងមូលមានទំហំធំៗ ងាយស្រួលក្នុងការរៀបចំ ឬអភិវឌ្ឍនៅថ្ងៃអនាគត។



## III-ប្រាសាទ និងស្ថានីយបុរាណរកឃើញថ្មីៗក្នុងស្រុកត្រពាំងប្រាសាទ

មុននឹងចាប់ផ្តើមចុះស្រាវជ្រាវរុករកស្ថានីយក្នុងស្រុកត្រពាំងប្រាសាទទាំងមូល មន្ត្រីជំនាញបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា រួមមាន លោក ហឿង សុធារស់, លោក ជ័យ រតនា, លោក ឃិន សាវន់ និងកញ្ញា ជុំ វិជ្ជតា ដែលដឹកនាំដោយ លោក ផុន កសិកា ប្រធានផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ និងចូលរួមដោយមន្ត្រីនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ គឺ លោក ឡេង វិទ្យា និងដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដីស្រុកត្រពាំងប្រាសាទ ពិសេសដោយមានការចូលរួមសហការនិងសម្របសម្រួលរបស់លោក ផុន ជាកុសល អភិបាលរងស្រុកត្រពាំងប្រាសាទ យើងបានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយមួយដល់មេឃុំ, ក្រុមប្រឹក្សាឃុំ, មេប៉ុស្តិ៍ និងមេភូមិ នៅក្នុងស្រុកទាំមូល។ កម្មវិធីផ្សព្វផ្សាយនេះបានចូលរួមជាអធិបតីដោយឯកឧត្តម ជុំ ជាតិ ជាសមាជិកក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ។ គោលបំណងនៃកម្មវិធីអប់រំផ្សព្វផ្សាយនេះគឺ៖ ផ្សព្វផ្សាយពីលទ្ធផលស្រាវជ្រាវស្តីអំពីប្រាសាទត្រពាំងប្រាសាទ, ធ្វើការសហការជាមួយអាជ្ញាធរស្រុកក្នុងការអភិរក្សប្រាសាទត្រពាំងប្រាសាទ ដោយខាងអាជ្ញាធរស្រុកត្រូវចូលរួម ថែទាំប្រាសាទ, រៀបចំកំណត់ព្រំដីរបស់ប្រាសាទត្រពាំងប្រាសាទឲ្យបានច្បាស់លាស់ ជៀសវាងការទន្ទ្រានវាតយកដីពីសំណាក់ប្រជាជន ទៅលើដីរបស់ប្រាសាទ។ គោលបំណងនៃកម្មវិធីអប់រំផ្សព្វផ្សាយនេះមួយទៀត គឺការធ្វើសម្ភាសន៍ជាមួយមេឃុំ និងមេភូមិពីវត្តមានប្រាសាទបុរាណ និងស្ថានីយបុរាណនៅក្នុងភូមិស្រុករបស់ពួកគេ។ វិធីនេះបានជួយឲ្យក្រុមស្រាវជ្រាវបានដឹងថា នៅក្នុងស្រុកត្រពាំងប្រាសាទមានប្រាសាទ និងស្ថានីយបុរាណជាច្រើនទៀតក្រៅពីប្រាសាទត្រពាំងប្រាសាទទាំងពីរ។



រូបលេខ០១៖ កម្មវិធីផ្សព្វផ្សាយវប្បធម៌រៀបចំធ្វើនៅក្នុងការិយាល័យស្រុកត្រពាំងប្រាសាទ

ក្រៅពីការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ក្រុមស្រាវជ្រាវក៏បានដាក់ផ្លាកសញ្ញានៅផ្លូវជាតិ ដើម្បីប្រាប់អ្នកធ្វើដំណើរឲ្យដឹងថា មានប្រាសាទត្រពាំងប្រាសាទនៅទីនេះ។ យើងបានធ្វើផ្លាកបង្ហាញចំនួនពីរ៖ មួយដាក់នៅជាប់ថ្នល់ជាតិ និងមួយទៀតដាក់នៅលើផ្លូវនៅក្បែរប្រាសាទ។



រូបលេខ០២៖ សកម្មភាពដាក់ផ្លាកសញ្ញាចូលប្រាសាទត្រពាំងប្រាសាទរបស់មន្ត្រីស្រាវជ្រាវ និងប្រជាពលរដ្ឋ

ក្រោយពីទទួលបានទិន្នន័យពីប្រាសាទបុរាណ និងស្ថានីយបុរាណនៅតាមទីតាំងភូមិ និងឃុំរួចមក ក្រុមស្រាវជ្រាវបានចាប់ផ្តើមចុះទៅដល់ទីតាំងប្រាសាទ និងស្ថានីយបុរាណទាំងនោះ។ លទ្ធផលនៃការសិក្សារុករក យើងរៀបចំទៅតាមឃុំនីមួយៗ។

## ក-ឃុំត្រពាំងប្រាសាទ

ឃុំត្រពាំងប្រាសាទ ជាឃុំមួយដែលទីរួមស្រុកត្រពាំងប្រាសាទកសាង និងរៀបចំនៅក្នុងបរិវេណឃុំនេះ។ ឃុំត្រពាំងប្រាសាទមានព្រំប្រទល់ខាងលិចទល់នឹងឃុំអូរស្វាយ, ខាងកើតជាប់នឹស្រុកជាំក្សាន ខេត្តព្រះវិហារ, ខាងជើងទល់នឹងឃុំបាក់អន្លង់ និងខាងត្បូងជាប់នឹងស្រុកស្វាយលើ ខេត្តសៀមរាប។ ឃុំត្រពាំងប្រាសាទមានផ្ទៃដីទំហំ៨៧៨គីឡូម៉ែត្រក្រឡា ស្មើនឹង៨១៩៧៧ហិចតា ដែលធំជាងគេក្នុងចំណោមឃុំទាំងអស់ក្នុង ស្រុកត្រពាំងប្រាសាទ។ ឃុំត្រពាំងប្រាសាទមានភូមិចំនួន១៦ គឺ៖ ភូមិត្រពាំងប្រាសាទ, ភូមិទួលតាសេក, ភូមិឈូកស , ភូមិអូរសោម, ភូមិស្រះជ្រៃ, ភូមិព្រៃស្អាក, ភូមិថ្នល់កែង, ភូមិអូរក្រូច, ភូមិអូរគ្រាច, ភូមិទំនប់ថ្មី, ភូមិពានមាស, ភូមិអូររំដេង, ភូមិរលំត្បាល់, ភូមិស្រែកណ្តាល, ភូមិដីក្រហម និងភូមិស្រែក្រសាំង។

### ១-ប្រាសាទត្រពាំងប្រាសាទខាងត្បូង

ប្រាសាទត្រពាំងប្រាសាទមានពីរ ដែលមានចម្ងាយប្រមាណ៣០០ម៉ែត្រពីគ្នា។ នៅចន្លោះប្រាសាទទាំងពីរមានផ្លូវមួយភ្ជាប់ទៅកាន់ទីប្រជុំជនទីរួមស្រុក។ ទាក់ទងនឹងឈ្មោះប្រាសាទទាំងពីរ អ្នកស្រុកហៅឈ្មោះផ្សេងៗគ្នា។ ប្រាសាទនៅខាងត្បូងថ្នល់ មានឈ្មោះ**ប្រាសាទតូច**។ ចំណែកប្រាសាទខាងជើងថ្នល់មានឈ្មោះមួយថា **ប្រាសាទធំ។**

ប្រាសាទខាងត្បូង (X= ៤៣០៤១២, Y= ១៥៦៩៩១០) មានទីតាំងស្ថិតនៅខាងជើងទីប្រជុំជននៃទីរួមស្រុកត្រពាំងប្រាសាទ។ ការរៀបចំទីរួមស្រុក បន្ទាប់ពីសង្គ្រាមស៊ីវិលអូសបន្លាយអស់ជាច្រើនឆ្នាំ វត្តមួយបានរៀបចំកសាងឡើងនៅខាងលិចនៃប្រាសាទ។ នៅខាងជើងប្រាសាទតូច ឬប្រាសាទខ្នាចារ មានប្រាសាទ

មួយទៀតដូចដែលបានរៀបរាប់ខាងលើ គឺ ប្រាសាទធំ។ ប្រាសាទទាំងពីរសុទ្ធតែមានតដាកនៅចំពីមុខ គឺនៅចំទិសខាងកើតនៃប្រាសាទ។ តដាកស្ថិតនៅមុខប្រាសាទតូចមានទំហំធំជាងតដាកនៅខាងកើតប្រាសាទធំ។

ប្រាសាទខាងត្បូងជាប្រាសាទមានតួបី ដែលតួទាំងបីសង់លើខឿនតែមួយ ហោត្រៃ មានកស្សិណទឹកព័ទ្ធជុំវិញ, កំពែងថ្មបាយក្រៀម និងមានក្លោងទ្វារនៅគ្រប់ទិសទាំងបួន ទិសខាងកើត លិច ជើង និងនៅខាងត្បូង។




រូបលេខ២០៣៖ ប្រាង្គទាំងបីនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង


រូបលេខ២០៤៖ បំណែកផ្តែរពីរផ្ទាំងផ្គុំគ្នា ស្ថិតក្នុងបរិវេណប្រាសាទត្រពាំងប្រាសាទខាងត្បូង


រូបលេខ២០៥៖ លិង្គនៅក្នុងបរិវេណប្រាសាទត្រពាំងប្រាសាទខាងត្បូង





រូបលេខ២០៦ និងលេខ២០៧៖ កូនក្រឡដែលអ្នកស្រុកប្រមូលពីទួលបុរាណនៅជិតប្រាសាទត្រពាំងប្រាសាទខាងត្បូង

ប្រាសាទខាងត្បូង អាចសិក្សាពីងាយុកាលបានតាមរយៈផ្តែរពីរបំណែកក្នុងបរិវេណប្រាសាទ។ ផ្តែរពីរបំណែកនេះបែកចេញពីផ្តែរតែមួយ។ បំណែកទាំងពីរជាផ្នែកកណ្តាលនិងក្រោមនៃផ្តែរ។ បើយើងវិភាគទៅលើក្បាច់លម្អនៅលើផ្តែរ ផ្តែរនេះមានក្បាច់លម្អប្រហែលគ្នានឹងផ្តែររចនាបថកោះកេរ និងផ្តែររចនាបថប្រែរូប។

ប្លង់ប្រាសាទក៏ជាភស្តុតាងមួយអាចឲ្យយើងសិក្សាបានពីអាយុកាលដែរ។ ប្រាសាទតូចសង់ឡើង ដោយមានប្រាង្គបីលើទួលលើកខ្ពស់មួយ ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងកសិណទឹក។ កំពែងថ្មបាយក្រៀមមានគោបុរៈបួន ដែលគោបុរៈធំស្ថិតនៅខាងកើតដែលជាច្រកសំខាន់ជាងគេ។ ប្លង់ប្រាសាទបែបនេះ អាចដូចគ្នានឹងប្លង់ប្រាសាទសង់ក្នុងរចនាបថប្រែរូប។

សរុបមក ការសន្និដ្ឋានឲ្យជាក់ច្បាស់ពីអាយុកាលនៃប្រាសាទតូចមិនអាចធ្វើបានឡើយ។ ការសន្និដ្ឋានដំបូងពីអាយុកាលនៃប្រាសាទនេះ គឺប្រហែលក្នុងសតវត្សទី១០ ក្នុងរចនាបថកោះកេរ និងប្រែរូប។


Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter
(JICA GIS Dataset 2002)
Location Diagram

## ២-ប្រាសាទត្រពាំងប្រាសាទខាងជើង

ប្រាសាទត្រពាំងប្រាសាទខាងជើង (X= ៤៣០៣៩៧, Y= ១៥៧០០៩៥) ស្ថិតនៅខាងជើងទីប្រជុំជនស្រុកត្រពាំងប្រាសាទ គឺក្នុងឃុំត្រពាំងប្រាសាទ នៅខាងជើងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូងដែរ។

ប្រាសាទធំជាប្រាសាទមានប្រាង្គទោល មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ហោត្រៃស្ថិតនៅទិសឦសាន និងមានក្លោងទ្វារតែមួយគត់ ស្ថិតនៅទិសខាងកើត។ ប្រាសាទធំពុំមានកស្សិណទឹកព័ទ្ធជុំវិញដូចប្រាសាទតូចទេ តែមានតដាកមួយស្ថិតនៅខាងកើតនៃប្រាសាទ។ តដាកនេះមានទំហំបណ្តោយ ២០០ម៉ែត្រ និងទទឹង៩១ម៉ែត្រ និងផ្ទៃក្រឡាជាង ២០០០០ម៉ែត្រក្រឡា។




ប្រាសាទត្រពាំងប្រាសាទខាងជើងក៏មានកំពែងដូចប្រាសាទខាងត្បូងដែរ។ កំពែងប្រាសាទធំសង់ពីថ្មបាយក្រៀម។ កំពែងនេះមានទទឹងពីជើងទៅត្បូងប្រវែង២៣ម៉ែត្រ និងបណ្តោយពីកើតទៅលិចប្រវែង៣៥ម៉ែត្រ។ ប្រាសាទធំពុំមានក្លោងទ្វារចូលបួននៅគ្រប់ទិស គឺមានតែក្លោងទ្វារតែមួយគត់នៅជ្រុងខាងកើត។ ក្លោងទ្វារខាងកើតធ្វើពីថ្មបាយក្រៀមនិងសុំទ្វារធ្វើពីថ្មភក់។



រូបភាពលេខ០៨៖ ក្លោងទ្វារនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម នៅជ្រុងខាងកើត

ប្រាសាទខាងជើងមានប្រាង្គតែមួយគត់មានកម្ពស់៦ម៉ែត្រ សង់ពីថ្មបាយក្រៀម និងថ្មភក់សម្រាប់ស៊ុំទ្វារ។ ប្រាង្គនេះមិនមានក្បាច់រចនាលើទេ។ យើងមិនប្រទះឃើញបំណែកហោជាង ផ្តែរ សសរស្តម្ភនៅក្នុងបរិវេណប្រាសាទទេ។ សូម្បីគោបុរៈនៃប្រាសាទក៏មិនមានក្បាច់លម្អណាមួយដែរ។

ទាក់ទងនឹងការពុកផុយនៃប្រាសាទ ជញ្ជាំងខាងជើងនៃប្រាង្គបានធ្លាក់បាក់រលំ ដុំថ្មបាយក្រៀមនៃប្រាង្គធ្លាក់គលើគ្នានៅជ្រុងខាងជើងនេះ។ តាមការសង្កេតពីសណ្ឋានដីជុំវិញប្រាសាទ យើងឃើញថា ប្រាសាទនេះសង់នៅលើដីធម្មជាតិ ដោយមិនមានលើកដីជាធ្លាទេ។ នៅភាគខាងជើងជិតប្រាសាទ ដីជម្រាលចុះ។ សណ្ឋានដីបែបនេះអាចប៉ះពាល់ដល់សំណង់ប្រាសាទ ពីព្រោះនៅពេលមានភ្លៀងធ្លាក់ ទឹកបាននាំដីហូរច្រោះទៅភាគខាងជើង។ ទឹកហូរពីទីខ្ពស់មកទាប គឺហូរពីប្រាង្គទៅភាគខាងជើង ធ្វើឲ្យដីហូរជាច់។ ដូច្នេះហើយបានជា កំពែងជ្រុងខាងជើង និងជញ្ជាំងប្រាង្គខាងជើងបាក់បែកខ្លាំង។



រូបលេខ០៩៖ ប្រាង្គកណ្តាលនៃប្រាសាទខាងជើងមើលពីទិសខាងកើត សង់ពីថ្មបាយក្រៀម

ហោត្រៃជាអគារបុរាណនៅក្នុងបរិវេណប្រាសាទ ជាទូទៅបែរមុខបញ្ច្រាសទិសនឹងប្រាង្គកណ្ដាលនៃប្រាសាទ។ ហោត្រៃនៃប្រាសាទធំសង់ពីថ្មបាយក្រៀម និងមានថ្មភក់សង់សម្រាប់ស៊ុំទ្វារ។ ហោត្រៃនេះទំហំ៥ម៉ែត្រពីកើតទៅលិច និង៣ម៉ែត្រពីជើងទៅត្បូង។



រូបលេខ១០៖ ហោត្រៃប្រាសាទត្រពាំងប្រាសាទខាងជើង



ប្រាសាទត្រពាំងប្រាសាទខាងជើងមានរូបរាង និងប្លង់ដូចគ្នានឹងមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានកសាងនៅតាមផ្លូវបុរាណក្នុងរាជរបស់ព្រះអង្គ។



ប្លង់មន្ទីរពេទ្យនៃប្រាសាទសំរោង (ប្រភពៈ អ៊ា ដារិទ្ធ)


Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter
(JICA GIS Dataset 2002)
Location Diagram

### ៣-ប្រាសាទរលំទឹកខ្មៅ

ប្រាសាទរលំទឹកខ្មៅ (X= ៤៤២៤៨៣, Y= ១៥៦៦០៧៩) ស្ថិតក្នុងភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ។ ប្រាសាទរលំទឹកខ្មៅជាប្រាសាទសង់ពីឥដ្ឋ ថ្មបាយក្រៀម និងថ្មភក់។ តួប្រាសាទសង់ពីឥដ្ឋ កំពែង និងខឿនប្រាសាទសង់ពីថ្មបាយក្រៀម ចំណែកថ្មភក់ប្រើសម្រាប់គ្រឿងលម្អ ដូចជាមេទ្វារ ផ្តែរ សសរស្តម្ភ ហោជាង ជាដើម។ ប្រាសាទ រលំទឹកខ្មៅបែមុខទៅទិសខាងកើត ជាប្រាសាទមានតួបី សង់លើខឿនថ្មបាយក្រៀម មានកំពែងព័ទ្ធជុំវិញ និងមានក្លោងទ្វារនៅទិសខាងកើត និងខាងលិច។ ក្លោងទ្វារទិសខាងកើតជាក្លោងទ្វារធំ។ មានហោត្រៃមួយសង់ពីឥដ្ឋ បែរមុខទៅកេតួប្រាសាទទាំងបី។ មានសំណង់គូទឹកសង់ព័ទ្ធជុំវិញ កំពែងថ្មបាយក្រៀម។ ប្រាសាទនេះមិនមានក្បាច់ចម្លាក់នៅលើផ្តែរ និងសសរស្តម្ភទេ។

សំណង់ប្រាសាទដែលមានតួប្រាសាទ មានហោរត្រៃ និងកំពែងព័ទ្ធជុំវិញដែលមានក្លោងទ្វារចូលប្រាសាទនៅខាងកើត និងខាងលិច។ លក្ខណៈសំណង់បែបនេះ ដូចគ្នានឹងប្រាសាទត្រពាំងប្រាសាទខាងត្បូង។ ដូច្នេះ យ៉ាងហោចណាស់យើងអាចដឹងថា ប្រាសាទរលំទឹកខ្មៅកសាងនៅប្រហែលសតវត្សទី១០។

ស្ថានភាពបច្ចុប្បន្ននៃប្រាសាទ គឺមានព្រៃដុះស៊ប់ទ្រប់នៅលើតួប្រាសាទ និងក្នុងបរិវេណប្រាសាទ។ រុក្ខជាតិទាំងអស់នេះជាលម្អមួយដល់ប្រាសាទ ក៏ប៉ុន្តែត្រូវមានការរៀបចំ និងថែរទាំ។ ប្រាសាទនេះមិនមានការថែរទាំជាច្រើនឆ្នាំមកហើយ ដូចនេះ ប្រាសាទរលំទឹកខ្មៅទាមទារឲ្យមានការយកចិត្តដាក់ថែទាំ សម្រាប់ការរៀបចំជាតំបន់ទេសចរណ៍ក្នុងស្រុក ក៏ដូចជាទេសចរអន្តរជាតិ។



រូបលេខ១១៖ ប្រាសាទរលំទឹកខ្មៅ



រូបលេខ១២៖ ហោត្រៃនៃប្រាសាទរលំទឹកខ្មៅ



រូបលេខ១៣៖ តួប្រាសាទខាងជើង និងខឿនប្រាសាទថ្មបាយក្រៀម

ផែនទីបង្ហាញទីតាំងប្រាសាទលើនឹកខ្មៅ ស្ថិតនៅ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ៤-ទួលប្រាសាទអូរសោម

ទួលប្រាសាទអូរសោម (X= ៤៤០០៥៩, Y= ១៥៦៤៦៣២) ស្ថិតក្នុងភូមិអូរសោម ភាគខាងកើតក្នុងព្រៃឆ្ងាយពីភូមិ។ ទួលប្រាសាទនេះ មានប្រវែង៣០ម៉ែត្រ និងគូទឹកព័ទ្ធជុំវិញ ប្រវែង១០ម៉ែត្រ។ នៅលើទួលមានស្នាមដីករកវត្ថុបុរាណ ទំហំប្រហែល ៤ម៉ែត្រ។ នៅក្បែររណ្តៅដីកនោះ មានថ្មបាយក្រៀម និងថ្មភក់។ ថ្មបាយក្រៀមគឺជាសមាសធាតុសំណង់ប្រាសាទ ឬជាសំណង់តូចមួយ រីឯថ្មភក់គឺជាបល័ង្ក។ ទួលប្រាសាទអូរសោមស្ថិតក្នុងព្រៃក្រាស់មានដើមឈើធំៗដុះជុំជិត។ នៅមិនឆ្ងាយពីទួលប្រាសាទនេះ មានភូមិបុរាណដែលមានបំណែកកុលាលភាជន៍នៅរាយប៉ាយជាច្រើន។ បំណែកកុលាលភាជន៍ភាគច្រើនជាប្រភេទរឹង ដែលបង្ហាញអំពីអាយុកាលនៃបំណែកភាជន៍ក្នុងសម័យអង្គរ។ នៅមិនឆ្ងាយពីទួលប្រាសាទ និងភូមិបុរាណ នៅមានត្រពាំងបុរាណជាច្រើនទៀត។ លក្ខណៈបែបនេះបង្ហាញពីការតាំងទីលំនៅបុរាណជាសហគមន៍ដែលមានភូមិដ្ឋាន ត្រពាំង និងទីទួលសម្រាប់គោរពបូជា។



រូបលេខ១៤៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទភូមិអូរសោម





រូបលេខ១៥ និង១៦៖ ថ្មភក់ និងថ្មបាយក្រៀមដែលជាសំណល់សំណង់គោរពបូជាលើទួលភូមិអូរសោម



រូបលេខ១៧៖ បំណែកកុលលាភាជន៍យកពីទួលមនុស្សរស់នៅជិតទួលប្រាសាទអូរសោម



## ៥-ប្រាសាទរលំធ្លោ

ប្រាសាទរលំធ្លោស្ថិតក្នុងទីតាំង (X= ៤៤៣០៨៨, Y= ១៥៦០៤០៨) គឺជាប្រាសាទទោល ទំហំ៣ម៉ែត្រ និង២ម៉ែត្រ សង់ពីថ្មបាយក្រៀម និងគ្រឿងសំណង់ដូចជាផ្តែរសង់ពីថ្មភក់។ ប្រាសាទទោលនេះសង់លើទួលទំហំប្រវែង៣០ម៉ែត្រ និងមានគូទឹកសង់ព័ទ្ធជុំវិញទួល។ នៅលើទួលមានបំណែកផ្តែរ និងបំណែកមេទ្វារ ព្រមទាំងដុំថ្មភក់ជាច្រើនទៀត។ ប្រាសាទនេះស្ថិតកណ្តាលព្រៃ ឆ្ងាយពីភូមិ ដែលមានមនុស្សតិចណាស់ស្គាល់ទីតាំងរបស់វា។



រូបលេខ១៨៖ តួប្រាសាទរលំធ្លោសង់ពីថ្មបាយក្រៀម





រូបលេខ១៩ និង២០៖ បំណែកផ្តែរដែលស្ថិតនៅលើទួលប្រាសាទរលំធ្លោ


JICA GIS Dataset 2002
Location Diagram
Coordinate System : UTM
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៦-ប្រាសាទអូរចំបក់

ប្រាសាទអូរចំបក់ (X= ៤៣៨៨៤៣, Y= ១៥៦៨៤៧០) ស្ថិតក្នុងភូមិអូរចំបក់ ឃុំត្រពាំងប្រាសាទ។ ប្រាសាទនេះជាប្រាសាទទោល សង់ពីថ្មបាយក្រៀម នៅលើទួលមួយ ដែលទួលព័ទ្ធជុំវិញដោយគូទឹក។ មិនមានឃើញសំណល់ផ្តែរ ឬសសរស្តម្ភ នៅក្បែរប្រាសាទទេ។ ផ្ទុយទៅវិញ ឃើញមានស្នាមជីកកកាយរកវត្ថុបុរាណនៅទល់មុខតួប្រាសាទ។ ចំណែកនៅក្នុងតួប្រាសាទ កណ្តៀរបានពូនដីពេញតួប្រាសាទ ក៏ប៉ុន្តែ ក្នុងតួប្រាសាទ ក៏មានការជីកកកាយរកវត្ថុបុរាណដែរ។ សំណង់បែបនេះ យើងមិនអាចសន្និដ្ឋានពីអាយុកាលនៃការសងសង់ប្រាសាទបានទេ។ តាមធម្មតា យើងអាចសន្និដ្ឋានពីអាយុកាលនៃការសាងសង់ប្រាសាទតាមរយៈសិលាចារឹក, តាមរយៈក្បាច់រចនានៅលើផ្តែរ នៅលើហោជាង ឬសសរស្តម្ភជាដើម។ បើពុំនោះទេ យើងអាចពឹងផ្អែកលើសំណង់ប្រាសាទ។ អ្វីដែលបន្សល់ទុកនៅ ប្រាសាទអូរចំបក់ គ្មានសញ្ញាណាមួយដែលយើងអាចសន្និដ្ឋានពីអាយុកាលនៃការសាងសង់បានសោះឡើយ។



រូបលេខ២១៖ តួប្រាសាទអូចំបក់សង់ពីថ្មបាយក្រៀម


(JICA GIS Dataset 2002)
Location Diagram
Coordinate System : UTM
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៧-ប្រាសាទតាគុញ

ប្រាសាទតាគុញ (X= ៤៣២៨១០, Y= ១៥៤១៨៣០) ស្ថិតក្នុងភូមិទំនប់ថ្មី ឃុំត្រពាំងប្រាសាទ ជិតព្រំដែនរវាងស្រុកត្រពាំងប្រាសាទ និងស្រុកស្វាយលើ ខេត្តសៀមរាប។ ប្រាសាទតាគុញជាប្រាសាទមានតួបីសង់ពីថ្មបាយក្រៀម និងសមាធាតុសំណង់ផ្សេងៗទៀតសង់ពីថ្មភក់។ ប្រាសាទនេះបែរមុខទិសខាងកើត ពុំមានសំណង់គូទឹក និងកំពែងទេ។ បំណែកហោជាងដែលនៅលើដី មានចម្លាក់រូប ប្រហែលជាលោកេសូរ។ សំណង់ប្រាសាទនេះមានលក្ខណៈប្លែក ពីប្រាសាទនានា។ ដោយសារ តួប្រាសាទសង់ពីថ្មបាយក្រៀម និងមានចម្លាក់រូបលោកេសូរនៅលើហោជាង ប្រាសាទនេះអាចកសាងក្នុងសតវត្សទី១៣ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។



រូបលេខ២២៖ តួប្រាសាទតាគុញសង់ពីថ្មបាយក្រៀម





រូបលេខ២៣ និង២៤៖ បំណែកហោជាង និងសសរស្តម្ភនៃប្រាសាទតាគុញ


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៨-ប្រាសាទល្បើកជ្រៃ

ប្រាសាទល្បើកជ្រៃ (X= ៤៣៩៤៣៤, Y= ១៥៤៦៩៣៤) ស្ថិតក្នុងភូមិពានមាស ឃុំត្រពាំងប្រាសាទ។ ប្រាសាទល្បើកជ្រៃមានតួប្រាសាទបីសង់លើខឿន ដែលតួទាំងបីសង់ពីឥដ្ឋ ស៊ុំទ្វារ ផ្តែរ សសរស្តម្ភ សង់ពីថ្មភក់។ មានកំពែងសង់ពីថ្មបាយក្រៀមព័ទ្ធជុំវិញ និងក្លោងទ្វារនៅភាគខាងកើត និងខាងលិច។ មានហោត្រៃមួយបែរមុខទៅរកតួប្រាសាទ។ ពុំមានក្បាច់រចនានៅលើប្រាសាទនេះទេ។

សំណង់ប្រាសាទដែលមានតួប្រាសាទបីសង់លើខឿន, ហោត្រៃមួយ, កំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ដូចគ្នានឹងប្រាសាទត្រពាំងប្រាសាទខាងត្បូង និងប្រាសាទរលំទឹកខ្មៅ។ តាមរយៈភស្តុតាងខាងលើ យើងអាចសន្និដ្ឋានថា ប្រាសាទល្បើកជ្រៃប្រហែលសាងសង់នៅសតវត្សទី១០។



រូបលេខ២២៥៖ ប្រាង្គទាំងបីនៃប្រាសាទល្បើកជ្រៃ



រូបលេខ២២៦៖ ហោត្រៃនៃប្រាសាទល្បើកជ្រៃ



រូបលេខ២២៧៖ កំពែងថ្មបាយក្រៀមខាងត្បូង និងខាងលិច



រូបលេខ២២៨៖ ប្រាង្គកណ្តាលនៃប្រាសាទល្បើកជ្រៃ



រូបលេខ២២៩៖ ប្រាង្គខាងជើងនៃប្រាសាទល្បើកជ្រៃ



រូបលេខ៣០៖ បំណែកបាតក្រឡយកពីទីតាំងក្បែរប្រាសាទល្បើកជ្រៃ



## ៩-ប្រាសាទកូនចិន

ប្រាសាទកូនចិន(X= ៤៤៤២២៨, Y= ១៥៤៣៣១៥)ស្ថិតក្នុងភូមិពានមាស ឃុំត្រពាំងប្រាសាទ គឺនៅជាប់ព្រំដែននៃខេត្តព្រះវិហារ។ ប្រាសាទកូនចិនជាប្រាសាទដែលមានរចនាសម្ព័ន្ធសំណង់ស្មុគស្មាញជាងប្រាសាទនានាដែលបានរៀបរាប់រួចមកហើយ។ ថ្មភក់ជាថ្មសំខាន់ជាងគេក្នុងសមាសធាតុសំណង់ប្រាសាទនេះ។ ចំណែកថ្មបាយក្រៀមសង់សម្រាប់កំពែង។ ប្រាសាទនេះមានកំពែង និងក្លោងទ្វារតែមួយគឺនៅទិសខាងកើត។ ដោយសារមិនមានអ្វីសម្រាប់បង្ហាញពីភាពច្បាស់លាស់នៃអាយុកាលនៃការសាងសង់ យើងអាចហ៊ានត្រឹមសន្និដ្ឋានថា ប្រាសាទកូនចិនអាចកសាងនៅដើមសតវត្សទី១១។


រូបលេខ៣១៖ តួប្រាសាទកូនចិន


រូបលេខ៣២៖ ក្លោងទ្វារខាងកើតនៃប្រាសាទកូនចិន


រូបលេខ៣៣៖ កំពែងថ្មបាយក្រៀមនៃប្រាសាទកូនចិន


រូបលេខ៣៤៖ បំណែកកុលាលភាជន៍យកពីទីទួលក្បែរប្រាសាទកូនចិន


ផែនទីបង្ហាញទីតាំងប្រាសាទប្រាសាទកុកចិន ស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ១០-ប្រាសាទជិតប្រាសាទកូនចិន

ប្រាសាទនេះមិនមានឈ្មោះហៅទេ។ អ្នកស្រុកភូមិដែលរស់នៅក្នុងភូមិពានមាស និងអ្នកស្រុកឆ្លងកាត់តំបន់ប្រាសាទនេះមិនដែលស្គាល់ប្រាសាទនេះទេ។ ប្រាសាទនេះស្ថិតនៅមិនឆ្ងាយពីប្រាសាទកូនចិន និងប្រាសាទភ្នំសណ្តកឡើយ ស្ថិតនៅចំណុច(X= ៤៤៤១៥៦, Y= ១៥៤២៧០៣)។ ដូចនេះហើយ យើងក៏ហៅប្រាសាទនេះជាបណ្តោះអាសន្នថា "ប្រាសាទជិតប្រាសាទកូនចិន"។

ប្រាសាទជិតប្រាសាទកូនចិន ជាប្រាសាទទោល សង់ពីថ្មបាយក្រៀម មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ និងក្លោងទ្វារនៅទិសខាងកើត។ មានហោត្រៃមួយសង់ពីថ្មបាយក្រៀម។ នៅជ្រុងឦសាននៃកំពែង មានត្រពាំងតូចមួយ នៅភាគខាងកើតមានត្រពាំងធំ។ មិនមានក្បាច់លម្អលើផ្តែរ ឬសសរស្តម្ភឡើយ។ លក្ខណៈសំណង់បែបនេះដូចគ្នាទៅនឹងសំណង់ប្រាសាទត្រពាំងប្រាសាទខាងជើង។ ដូច្នេះ ប្រាសាទជិតប្រាសាទកូនចិនអាចជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលកសាងនៅក្នុងសតវត្សទី១៣។



រូបលេខ៣៥៖ តួប្រាសាទ (ទិសខាងកើត)ដែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧



រូបលេខ៣៦៖ តួប្រាសាទ (ទិសខាងលិច)ដែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧



រូបលេខ៣៧៖ បំណែកកុលាលភាជន៍យកពីភូមិបុរាណនៅជិតប្រាសាទជិតប្រាសាទកូនចិន



## ១១-ប្រាសាទភ្នំសណ្ដក

ប្រាសាទភ្នំសណ្ដក(X= ៤៤៤១១០, Y= ១៥៤៤០៧០)ជាប្រភេទសំណង់ប្រាសាទមានលក្ខណៈស្មុគស្មាញ និងសាងសង់បន្តពីរាជ្យមួយទៅរាជ្យមួយទៀត ដែលមានរចនាបថខុសៗគ្នា។ ប្រាសាទភ្នំសណ្ដកសាងលើចង្កេះភ្នំមួយឈ្មោះភ្នំសណ្ដក។ ភ្នំសណ្ដកជាភ្នំមានរយៈកំពស់មិនលើសពី១០០ម៉ែត្រ និងពុំមានទីធ្លាធំនៅលើកំពូលទេ។ ដូច្នេះហើយ គេមិនអាចសង់ប្រាសាទនៅលើភ្នំបាន ក៏សង់នៅចង្កេះភ្នំវិញ។ បច្ចេកទេសនៃការសាង់សង់ គឺតម្រូវឲ្យកាត់ថ្មភ្នំនៅតាមចង្កេះភ្នំឲ្យរាបស្មើ ដើម្បីពង្រីកធ្លាឲ្យធំ មុននឹងចាប់ផ្ដើមសង់ប្រាសាទ។ វត្ថុជាតុសម្រាប់សំណង់ប្រាសាទ មានឥដ្ឋ, ថ្មភក់, និងថ្មបាយក្រៀម។ ប្រាសាទនេះមានតួប្រាសាទច្រើនសង់ក្នុងឆ្នាំខុសគ្នាៗ។ បន្ទុំប្រាសាទទាំងនោះ ព័ទ្ធជុំវិញដោយកំពែងពីរជាន់ដែលមានក្លោងទ្វារនៅទិសខាងកើត។ ក្រៅពីកំពែងទាំងពីរ នៅមានសំណង់កំពែង សង់លើកំពូលភ្នំ គឺនៅភាគខាងត្បូង។ នៅភាគខាងត្បូងនេះដែរ ក៏មានសំណង់ជណ្ដើរឡើងភ្នំសង់ពីថ្មបាយក្រៀម។ នៅលើមេទ្វារនៃក្លោងទ្វារកំពែងទី២ មានចារសិលាចារឹកដែលមានព្រះនាមព្រះបាទសូរ្យវរ្ម័នទី១។

ដូច្នេះ យ៉ាងហោចណាស់ យើងអាចសន្និដ្ឋាថា ក្នុងដំណាក់កាលណាមួយនៃការសាងសង់ប្រាសាទភ្នំសណ្ដក គឺកសាងក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ ក្នុងសតវត្សទី១១។

ប្រាសាទនេះ ទាមទារឲ្យមានការសិក្សាលម្អិត ដោយចំណាយពេលវេលាឲ្យបានគ្រប់គ្រាន់ ដើម្បីសិក្សាស្វែងយល់ពីអាយុកាលនៃសំណង់, រចនាបថ និងបច្ចេកទេសសាងសង់ជាដើម។



រូបលេខ៣៨៖ ក្លោងទ្វារកំពែងទី១នៃប្រាសាទភ្នំសណ្ដក



រូបលេខ៣៩៖ ក្លោងទ្វារកំពែងទី២នៃប្រាសាទភ្នំសណ្ដក



រូបលេខ៤០៖ សិលាចារឹកចារលើក្លាងទ្វារនៃកំពែងទី២ ដែលមានព្រះនាមរបស់ព្រះបាទសូរ្យវរ្ម័នទី១



រូបលេខ៤១៖ ផ្តែរនៃតួប្រាសាទ



រូបលេខ៤២៖ ផ្តែរនៅលើក្លោងទ្វារកំពែងទី២



រូបលេខ៤៣៖ បំណែកកុលាលភាជន៍ជាប្រភេទរឹង និងផុយប្រមូលពីទីតាំងភ្នំសណ្តក



រូបលេខ៤៤៖ បំណែកកុលាលភាជន៍ប្រមូលពីទីតាំងភ្នំសណ្តក


ផែនទីបង្ហាញទីតាំងប្រាសាទខ្ទឹមសណ្ដក ស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ១២-ប្រាសាទចាក់ប្រែង

ប្រាសាទចាក់ប្រែង(X= ៤៣៥០៥៤, Y= ១៥៣៦៩៣៥)ស្ថិតក្នុងភូមិពានមាស ឃុំត្រពាំងប្រាសាទ។ ប្រាសាទចាក់ប្រែងមានតួប្រាសាទទោល សង់ពីថ្មភក់។ ប្រាសាទនេះមានកំពែងព័ទ្ធថ្មបាយក្រៀមជុំវិញ ហើយមានគូទឹកព័ទ្ធជុំវិញកំពែង ដោយទុកផ្លូវចូលទៅប្រាសាទនៅទិសខាងកើត។ ប្រាសាទនេះសង់ជាប់ប្រាសាទឥដ្ឋ ដែលតួប្រាសាទនៅជាប់ខាងលិចនៃតួប្រាសាទនេះ។ តាមការសន្និដ្ឋានដំបូង គូទឹកប្រហែលជាកសាងដំណាលគ្នាជាមួយនឹងតួប្រាសាទឥដ្ឋ។ ទោះយ៉ាងណា យើងមិនអាចដឹងថា តើតួប្រាសាទឥដ្ឋកសាងក្នុងឆ្នាំណាទេ? លុះដល់ពេល ប្រាសាទនេះកសាងឡើង គេនៅរក្សាគូទឹកដដែល ប៉ុន្តែគេសង់ក្លោងទ្វារថ្មភក់នៅខាងក្រៅគូទឹកនៅភាគខាងកើត។

មានសមាសធាតុសំណង់ច្រើននៅក្នុងបរិវេណប្រាសាទនេះ ដូចជា ផ្តែរ, បំណែកហោជាងដែលឆ្លាក់ចម្លាក់រូបរាហ៊ូ និងព្រះកាល។

តាមរយៈភស្តុតាង និងរចនាសម្ព័ន្ធសំណង់ ប្រាសាទនេះប្រហែលកសាងក្នុងសតវត្សទី១១។

នេះគឺជាទិន្នន័យដំបូង យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាលម្អិតពីប្រាសាទនេះឡើយ។



រូបលេខ៤៥៖ ប្រាង្គប្រាសាទចាក់ប្រែង



រូបលេខ៤៦៖ ផ្តែរស្ថិតក្នុងបរិវេណប្រាសាទចាក់ប្រែង



រូបលេខ៤៧៖ ផ្តែរមួយទៀតក្នុងបរិវេណប្រាសាទចាក់ប្រែង ត្រូវបំផ្លាញនៅផ្នែកកណ្តាល



រូបលេខ៤៨៖ បំណែកហោជាងមានរូបរាហ៊ូនៅប្រាសាទចាក់ប្រែង



រូបលេខ៤៩៖ បំណែកផ្តែរនៃប្រាសាទចាក់ប្រែង



## ១៣-ទួលប្រាសាទភូមិថ្កូវ ឬទួលប្រាសាទភូមិអភិវឌ្ឍថ្មី

ទួលប្រាសាទភូមិថ្កូវ ឬអភិវឌ្ឍថ្មី (X= ៤៣១២១០, Y= ១៥៤៦៩៧៦) ស្ថិតក្នុងភូមិអភិវឌ្ឍថ្មី ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ។ ទួលប្រាសាទភូមិថ្កូវ មានកសិណព័ទ្ធជុំវិញ ហើយនៅមានដុំថ្មបាយក្រៀមជាច្រើននៅលើទួល។



រូបលេខ៥០៖ ទួលប្រាសាទភូមិថ្កូវមានគូទឹកព័ទ្ធជុំវិញ





រូបលេខ៥១ និង៥២៖ បំណែកថ្មបាយក្រៀមស្ថិតលើទួលប្រាសាទភូមិថ្កូវ



(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ១៤-ស្ថានីយយកថ្មបាយក្រៀម

កន្លែងយកថ្មបាយក្រៀមមួយ(X= ៤៣៧៥១១, Y= ១៥៤៥៨១៥)បានរកឃើញនៅក្នុងភូមិពានមាស។ ការយកថ្មបាយក្រៀម គឺជាការជីកចុះក្នុងដី ព្រោះថ្មបាយក្រៀមស្ថិតក្នុងដី។ យើងមិនអាចវាស់ពីទំហំនៃទីតាំងយកថ្មបាយក្រៀមនេះបានទេ ដោយសារព្រៃក្រាស់ មិនអាចមើលដឹងពីទំហំបាន។



រូបលេខ៥៣៖ ទីតាំងយកថ្មបាយក្រៀមនៅក្នុងភូមិពានមាស





រូបលេខ៥៤ និង៥៥៖ ទីតាំងយកថ្មបាយក្រៀម នៅភូមិពានមាស


Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter
(JICA GIS Dataset 2002)

## ១៥-ស្ថានីយយកថ្មភក់ និងសិប្បកម្មចម្លាក់ថ្មភក់

ទីតាំងយកថ្មភក់មួយ(X= ៤៤៤៤៤៨, Y= ១៥៤២៨១៧)បានរកឃើញនៅចន្លោះរវាងប្រាសាទកូនចិន និងប្រាសាទជិតប្រាសាទកូនចិន។ ទីតាំងនេះគឺជាកន្លែងមានថ្មភក់ជាច្រើនកើតមានពីធម្មជាតិ។ យើងមើលឃើញថ្មភក់ធម្មជាតិនៅលើផ្ទៃ និងដុំថ្មភក់ដែលគេកាត់រួច។ ទីតាំងយកថ្មភក់ មានទំហំធំ។ ក្រៅពីថ្មភក់ យើងឃើញមានថ្មបាយក្រៀមដែលកាត់រួចហើយ នៅមានលើស្ថានីយនេះដែរ។



រូបលេខ៥៦៖ ទិដ្ឋភាពនៃស្ថានីយយកថ្មភក់ និងទីតាំងសិប្បកម្មថ្មភក់



## ១៦-ស្ថានីយយកថ្មបាយក្រៀម នៅភ្នំសណ្តក

ដូចបានរៀបរាប់ពីខាងលើ ស្តីអំពីប្រាសាទភ្នំសណ្តកខាងលើចង្កេះភ្នំសណ្តក។ ថ្មបាយក្រៀមជាវត្ថុធាតុចាំបាច់មួយសម្រាប់សំណង់ប្រាសាទខ្មែរបុរាណ ជាពិសេសប្រាសាទភ្នំសណ្តកនេះ។ យើងក៏បានប្រទះឃើញស្ថានីយយកថ្មបាយក្រៀមមួយកន្លែង(X= ៤៤៣៩៦៩, Y= ១៥៤៣៨៨៥)នៅចម្រេះភ្នំសណ្តក។ ភ្នំសណ្តកក្រៅពីប្រភពធនធានធម្មជាតិ ដូចជាអនុផលព្រៃឈើ និងសត្វព្រៃ ភ្នំសណ្តកនៅមានធនធានថ្មភក់ និងថ្មបាយក្រៀមសម្រាប់សំណង់ប្រាសាទ។ ដោយសារ ធនធានអាចរកបានក្នុងតំបន់សម្រាប់តម្រូវការសំណង់ប្រាសាទ បានជាមានប្រាសាទច្រើនសង់នៅតំបន់ភ្នំសណ្តកនេះ។



រូបលេខ៥៧៖ ទីតាំងយកថ្មបាយក្រៀម នៅជើងភ្នំសណ្តក



## ១៧-ថ្មគោល នៅជិតស្ពានីយយកថ្មបាយក្រៀមក្នុងភូមិពានមាស

ថ្មភក់មានរូបរាងដូចជាថ្មគោល(X= ៤៣៧៥០៦, Y= ១៥៤៥៨៦៣) បានរកឃើញនៅក្បែរស្ថានីយយកថ្មបាយក្រៀមក្នុងភូមិជើងពាន។ គោលនេះមានរាងជ្រុងមានបណ្ដោយប្រវែងមិនលើសពី១៣០សង់ទីម៉ែត្រ ទទឹង៥០សង់ទីម៉ែត្រ និងកម្រាស់៣០សង់ទីម៉ែត្រ។ នៅផ្នែកខាងលើនៃគោល មានក្បាច់ចិញ្ចាន និងកំពករាងដូចផ្កាឈូក។

យើងមិនអាចដឹងច្បាស់ថា តើថ្មគោលនេះប្រើសម្រាប់ជាសញ្ញាព្រំដី ឬជាគោលសម្គាល់នៅតាមផ្លូវបុរាណ។ នៅតំបន់ក្បែរនេះ អាចនឹងមានផ្លូវបុរាណសង់បំបែកពីផ្លូវបុរាណដែលសង់ពីប្រាសាទបឹងមាលា កាត់រាជធានីកោះកេរ្តិ៍ ទៅប្រាសាទនាគបួស មុននឹងទៅដល់ប្រាសាទវត្តភូក្នុងប្រទេសលាវបច្ចុប្បន្ន។ យើងសង្ស័យថា មានផ្លូវបុរាណកសាងបំបែកចេញពីផ្លូវខាងលើ ដើម្បីចូលមកដល់តំបន់ភ្នំសណ្ដក។ ការសិក្សាស្រាវលម្អិតត្រូវតែធ្វើបន្ត ដើម្បីស្វែងយល់ពីហេដ្ឋារចនាសម្ព័ន្ធនៃតំបន់ភ្នំសណ្ដក និងការធ្វើទំនាក់ទំនងរវាងតំបន់ភ្នំសណ្ដក និងតំបន់ផ្សេងៗដូចជា រាជធានីកោះកេរ្តិ៍ និងប្រាសាទព្រះវិហារ ក៏ដូចជាសហគមន៍នៅតាមជើងភ្នំដងរែក។



រូបលេខ៥៨៖ ថ្មគោលនៅជិតស្ថានីយយកថ្មបាយក្រៀមក្នុងភូមិពានមាស


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ១៨-ថ្មគោល នៅជិតប្រាសាទល្បើកជ្រៃ

ដូចគ្នានឹងថ្មភក់ខាងលើដែរ យើងបានរកឃើញថ្មភក់ជាថ្មគោល(X= ៤៣៩២៥០, Y= ១៥៤៦៧៦២) នៅជិតប្រាសាទល្បើកជ្រៃ។ ថ្មគោលនេះមានរាងជ្រុង មានបណ្តោយប្រវែង១៣០សង់ទីម៉ែត្រ ទទឹង៥០ សង់ទីម៉ែត្រ និងកម្រាស់៣០សង់ទីម៉ែត្រ។ នៅផ្នែកខាងលើនៃថ្មគោល មានក្បាច់ចិញ្ចាន និងកំពករាងដូច ផ្កាឈូក ដូចថ្មគោលនៅជិតស្ថានីយកថ្មបាយក្រៀមក្នុងភូមិជើងពានដែរ។

យើងក៏សង្ស័យថា អាចនឹងមានផ្លូវបុរាណកសាងកាត់តំបន់នេះ។ តាមរយៈ ប្រជាជនក៏បាននិយាយពី ផ្លូវបុរាណដែរ។ គេបានរៀបរាប់ថា ផ្លូវនោះប្រៀបដូចជាទំនប់លើកខ្ពស់ពីដី និងមានទំហំធំ ហើយវែង។ ដោយសារ ស្ថានភាពព្រៃស្តុក និងបញ្ហាគ្រាប់មីន និងអាវុធជាតិផ្ទុះ យើងមិនអាចដើររុកព្រៃ ស្វែងរកផ្លូវបុរាណ ឡើយ។

ការសិក្សាលម្អិត ដោយមានការសហការជាមួយអាជ្ញាធរជាតិដោះមីនកម្ពុជា ត្រូវធ្វើដើម្បីស្វែងរកផ្លូវ បុរាណ និងស្វែងយល់ពីហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច ជាមួយតំបន់ក្បែរនោះ។



រូបលេខ៥៩៖ ថ្មគោលនៅជិតប្រាសាទល្បើកជ្រៃ


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

ជាសរុបមក នៅក្នុងឃុំត្រពាំងប្រាសាទទាំងមល យើងបានរកឃើញប្រាសាទចំនួន និងទួលប្រាសាទចំនួន១៣, ស្ថានីយយកថ្មបាយក្រៀមចំនួន២កន្លែង, ស្ថានីយយកថ្មភក់ និងសិប្បកម្មចម្លាក់ថ្មភក់ចំនួន១កន្លែង និងថ្មគោលចំនួន២។ ជាក់ស្តែងការស្រាវជ្រាវរបស់យើងក៏បានសិក្សា និងកត់ត្រាអំពីត្រពាំងបុរាណដែរ ក៏ប៉ុន្តែយើងមិនបានលើកយកមករៀបរាប់ទេ។ ជាធម្មតា កាលណាមានសំណង់ប្រាសាទនៅទីណា ទីនោះគឺប្រាកដជាមានការជីកត្រពាំង។ នេះគឺទាក់ទងជំនឿនៃការប្រតិបត្តិសាសនាព្រាហ្ម។

ក្រៅពីសំណង់ប្រាសាទ និងបេតិកភណ្ឌដូចបានរៀបរាប់ខាងលើ នៅមានទំនប់បុរាណនៅជិតត្រពាំងទន្លេស្ងួត នៅក្បែរផ្លូវទៅប្រាសាទល្បើកជ្រៃ។ ទំនប់នេះមានលក្ខណៈ ស្រដៀងគ្នានឹងទំនប់នៅឃុំព្រះប្រឡាយ និងទំនប់បុរាណមួយទៀតស្ថិតក្នុងភូមិពានមាស នៅតាមផ្លូវ ចេញពីប្រាសាទភ្នំសណ្តក។

យើងបានរកឃើញទំនប់ដែលមានលក្ខណៈបែបនេះ ចំនួន៣។ រូបរាងនៃទំនប់ដូចគ្នានឹងផ្លូវបុរាណ ប៉ុន្តែមានទំហំតូចជាង ទាបជាង ជាពិសេសគឺប្រវែងមិនវែងនោះទេ។ សំណង់បែបនេះមានលក្ខណៈប្លែកពីសំណង់ផ្សេងៗ ដូចជា ត្រពាំង ផ្លូវបុរាណ។ ទំនប់ទាំងនេះគឺសង់តែមួយខ្សែ។ តាមការវិភាគ និងសន្និដ្ឋានជាដំបូង ទំនប់នេះសង់ដើម្បីទប់ រក្សាទឹកសម្រាប់ធ្វើស្រែនៅរដូវវស្សា។ ប៉ុន្តែ ទំនប់បែបនេះមិនអាចសង់បាននៅតំបន់ទំនាបបានទេ។ គេអាចសង់ទំនប់រក្សាទឹកតែមួយខ្សែបានបែបនេះ លុះណាតែតំបន់ក្បែរជើងភ្នំ។ យើងឃើញថា នៅជាប់នឹងទំនប់ទាំងបី មានវាលស្រែជាច្រើនហិចតា នៅដាំស្រូវដល់បច្ចុប្បន្ន។


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ខ-ឃុំអូរស្វាយ

ឃុំអូស្វាយស្ថិតនៅខាងជើងជាប់ជើងភ្នំដងរែកព្រំដែនប្រទេសថៃឡង់ដ៍, ខាងកើតឃុំត្រពាំងប្រាសាទ និងខាងត្បូងជាប់ឃុំត្រពាំងប្រាសាទ និងខាងលិចជាប់ឃុំផ្អាវ។ ឃុំអូរស្វាយមានផ្ទៃដីទំហំ២០២គីឡូម៉ែត្រក្រឡា ស្មើនឹង២៥៨២០ហិចតា។ ឃុំអូរស្វាយមានរចនាសម្ព័ន្ធភូមិ ដូចជា៖ ភូមិអូរល្ហុង, ភូមិអូរស្វាយ, ភូមិតាសំ, ភូមិពាមក្នុង, ភូមិឈើទាលជ្រុំ, ភូមិពពេលសែនជ័យ, ភូមិទំនប់អភិវឌ្ឍន៍, ភូមិទួលគ្រួស និងភូមិសែនសំ។

### ១៩-ប្រាសាទអូរស្វាយ

ប្រាសាទអូស្វាយ(X= ៤២៩៤៧៧, Y= ១៥៨២៥៤៦) ស្ថិតក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ស្ថិតក្នុងព្រៃឆ្ងាយពីភូមិ។ ប្រាសាទអូស្វាយជាប្រាសាទធំមួយក្នុងស្រុកត្រពាំងប្រាសាទ។ ប្រាសាទនេះមានតួមួយធ្វើពីថ្មបាយក្រៀម និងមានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ហើយនៅលើកំពែងមានសន្លឹករកាខ្លះទៀត។ ប្រាសាទអូរស្វាយមានបន្សល់ផ្តែរពីរដែលអាចសិក្សាពីអាយុកាលនៃប្រាសាទបាន។ នៅខាងកើតប្រាសាទ មានតដាកមួយធំ។ ដោយសារ តំបន់អូរស្វាយជាទីតាំងសម្បូរគ្រាប់មីន យើងមិនអាចសិក្សាធ្វើផែនទីបានទេ។



រូបលេខ២៦០៖ ប្រាសាទអូរស្វាយ





រូបលេខ២៦១ និង៦២៖ ផ្តែរ និងសន្លឹករកានៅក្នុងបរិវេណប្រាសាទអូរស្វាយ

ផែនទីបង្ហាញទីតាំងប្រាសាទមុខស្វាយ ស្ថិតនៅឃុំមុខស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ២០-ប្រាសាទត្រពាំងបី

ប្រាសាទត្រពាំងបី(X= ៤២៣២៣២, Y= ១៥៨០២៨៨) ស្ថិតក្នុងឃុំអូរស្វាយ ស្ថិតក្នុងព្រៃឆ្ងាយពីផ្លូវ។ ប្រាសាទត្រពាំងបីជាប្រាសាទតូចមានប្រាង្គទោល សង់ពីឥដ្ឋ។ ប្រាសាទនេះទទួលរងការបាក់បែកដោយសារធម្មជាតិនៅជុំវិញ និងការជីកកកាយរកវត្ថុបុរាណ។ យើងឃើញមានបំណែកថ្មភក់ ដែលជាមេទ្វារប្រាសាទ នៅរាយប៉ាយមុខប្រាសាទ។



## ២១-ទួលប្រាសាទទំនប់អភិវឌ្ឍន៍

ប្រាសាទទំនប់អភិវឌ្ឍន៍ (X= ៤២៤៤២៥, Y= ១៥៨៤១០៥) ស្ថិតក្នុងភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ។ ទួលប្រាសាទនេះមានស្នាមជីករកវត្ថុបុរាណនៅចំកណ្ដាលទួលគ្រឹះប្រាសាទ។ នៅលើទួលមានសំណល់ប្រាសាទដូចជា ផ្ដែរមួយ ចម្រឹងបង្អួច និងថ្មបញ្ចុះក្នុងគ្រឹះប្រាសាទ ដែលទំនងជាយកមកពីតំបន់ផ្សេង។



រូបលេខ២៦៣៖ ទួលប្រាសាទទំនប់អភិវឌ្ឍន៍មានផ្ដែរយកពីតំបន់ផ្សេង



## ២២-ប្រាសាទទួលគ្រួស

ប្រាសាទទួលគ្រួស(X= ៤៣៥២៣៧, Y= ១៥៨៥១៨៥)ស្ថិតក្នុងភូមិទួលគ្រួស ឃុំអូរស្វាយ។ ប្រាសាទនេះស្ថិនៅមិនឆ្ងាយពីជើងភ្នំដងរែកទេ។ ប្រាសាទទួលគ្រួសជាប្រាសាទតួតែមួយ សង់ពីថ្មភក់ និងមានគូទឹកព័ទ្ធជុំវិញ។ ប្រាសាទទួលគ្រួសមានព្រៃដុះស៊ប់ទ្រុប និងថែមទាំងមានដើមឈើដួលរលំពីលើ ធ្វើឲ្យថ្មប្រាសាទមួយចំនួនធ្លាក់ចេញពីតួប្រាសាទ។ ដោយសារព្រៃក្រាស់បែបនេះ យើងមិនអាចសិក្សាពីប្រាសាទនេះបាន ថាតើប្រាសាទសាងសង់ក្នុងឆ្នាំណា?




រូបលេខ៦៤ និង៦៥៖ តួប្រាសាទដែលសង់ពីថ្មភក់ ត្រូវដើមឈើរលំលើ និងរុក្ខជាតិផ្សេងៗដុះស៊ុបទ្រុបពីលើ



## ២៣-ថ្មគោល ក្នុងភូមិទួលគ្រួស

យើងក៏បានរកឃើញថ្មគោល(X= ៤៣៣៩៣៣, Y= ១៥៨១៧៨៦)នៅក្នុងភូមិទួលគ្រួសមួយទៀត។ យើងមិនអាចវាស់ប្រវែងរបស់ថ្មគោលបាន ដោយសារថ្មគោលនេះកប់ក្នុងដី។ បណ្តោយនៃថ្មគោលប្រហែល ១៣០សង់ទីម៉ែត្រ និងទទឹងប្រវែង៤៦សង់ទីម៉ែត្រ។

វត្តមានរបស់ថ្មគោលមួយទៀតក្នុងភូមិទួលគ្រួស រឹតតែធ្វើឲ្យយើងសន្និដ្ឋានថា តើមានផ្លូវបុរាណកសាងមកដល់តំបន់ត្រពាំងប្រាសាទនេះដែរឬទេ? នេះជាសំណួរសម្រាប់ការសិក្សាស្រាវជ្រាវទៅថ្ងៃខាងមុខ ដើម្បីរុករកផ្លូវបុរាណ។



រូបលេខ៦៦៖ ថ្មគោលធ្វើពីថ្មភក់ ក្នុងភូមិទួលគ្រួស



ជាសរុប នៅក្នុងឃុំអូរស្វាយមានប្រាសាទ និងទួលប្រាសាទចំនួន៤ និងថ្មគោល១។ ដូចគ្នានឹងឃុំត្រពាំងប្រាសាទដែរ ការសិក្សានេះមិនបានកត់ត្រាអំពីត្រពាំងនោះទេ។ ជាធម្មតា កាលណាមានសំណង់ប្រាសាទ ប្រាកដណាស់ គេពិតជាជីកត្រពាំងសម្រាប់បង្គ្រប់កិច្ចនៃប្រាសាទផង និងជីកត្រពាំងសម្រាប់ជីវិតទាំងមនុស្ស សត្វ ព្រមទាំងដំណាំផង។



## គ-ឃុំផ្អាវ

ឃុំផ្អាវជាឃុំមួយរបស់ស្រុកត្រពាំងប្រាសាទ មានព្រំប្រទល់ខាងលិចជាប់នឹងឃុំទឹកថ្លា ស្រុកអន្លង់វែង, ខាងជើងជាប់ភ្នំដងរែក, ខាងកើតជាប់ឃុំអូរស្វាយ និងខាងត្បូងជាប់នឹងឃុំត្រពាំងប្រាសាទ។ ឃុំផ្អាវមានផ្ទៃដីទំហំ១៩៨គីឡូម៉ែត្រក្រឡា ស្មើនឹង១៩៨២៨ហិចតា។ ឃុំផ្អាវមានភូមិចំនួន១០គឺ៖ ភូមិថ្កូវ, ភូមិថ្នល់កែង, ភូមិឫស្សី, ភូមិព្រះចំបក់, ភូមិអូរជីក, ភូមិផ្អាវ, ភូមិផ្តៀកជ្រុំ, ភូមិប្រោក, ភូមិពពេល និងភូមិអូរបេង។

ឃុំផ្អាវជាឃុំដែលមានបងប្អូនជនជាតិដើមមករស់នៅច្រើន ដែលពួកគេជាអតីតកម្លាំងរបស់ខ្មែរក្រហម ដែលកាលពីអតីតកាលពួកគេបានចូលរួមតស៊ូ តាំងពីនៅក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី។

តាមការសិក្សាស្រាវជ្រាវ យើងមិនបានរកឃើញប្រាសាទណាមួយនៅក្នុងឃុំផ្អាវទេ។ តែទោះយ៉ាងណា នៅមានទីដ្ឋានបុរាណគឺជាភូមិសម័យបុរាណដែលមនុស្សធ្លាប់រស់នៅ ជីកត្រពាំង ជាដើម។ យើងក៏បានសិក្សា និងកត់ត្រាទីតាំងបុរាណមួយស្ថិតក្នុងភូមិថ្នល់កែង។

### ២៤-ទួលភូមិបុរាណ និងត្រពាំងបុរាណ

ទួលភូមិបុរាណ និងត្រពាំងស្ថិតក្នុងភូមិថ្នល់កែង ឃុំផ្អាវ។ ទួលបុរាណមានច្រើន ទំហំធំៗ និងមានបំណែកកុលាលភាជន៍នៅតាមទួល។ ក្រៅពីនោះ នៅក្បែរទួលបុរាណ ក៏មានត្រពាំងបុរាណដែលគេជីកសម្រាប់រក្សាទឹកប្រើប្រាស់។



រូបលេខ២៦៧៖ បំណែកកុលាលភាជន៍ប្រមូលពីស្ថានីយក្នុងភូមិថ្នល់កែង ឃុំផ្អាវ

## ផែនទីបង្ហាញទីតាំងទួលភូមិ និងត្រពាំងបុរាណ ស្ថិតនៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ឃ-ឃុំបាក់អន្លង

ឃុំបាក់អន្លងមានព្រំប្រទល់ខាងលិចជាប់ឃុំអូរស្វាយ, ខាងត្បូងជាប់ឃុំត្រពាំងប្រាសាទ, ខាងជើងជាប់នឹងឃុំទំនប់ដាច់ និងខាងកើតជាប់ឃុំព្រះប្រឡាយ។ ឃុំបាក់អន្លងក៏មិនមានប្រាសាទ ឬទួលប្រាសាទច្រើនដូចឃុំផ្អាវដែរ។ យើងអាចកត់សម្គាល់តែទួលមួយគត់គឺទួលប្រសើរ។ ឃុំបាក់អន្លងមានផ្ទៃដី ទំហំ១៤១គីឡូម៉ែត្រក្រឡា ស្មើនឹង១៤១០០ហិចតា។ ឃុំបាក់អន្លងមានភូមិចំនួនចំនួន៥គឺៈ ភូមិទួលប្រសើរ, ភូមិមានជ័យ, ភូមិស្រែល្អ, ភូមិសំបូរ និងភូមិសុខសិរី។

### ២៥-ទួលប្រសើរ

ទួលប្រសើរ(X= ៤៣៤៧២៤, Y= ១៥៧១៧៣០) ស្ថិតក្នុងភូមិទួលប្រសើរ ឃុំបាក់អន្លង។ ទួលនេះមានទំហំធំ ក៏ប៉ុន្តែ យើងមិនអាចសិក្សាបាន ដោយសារព្រៃ និងស្មៅដុះក្រាស់ មិនអាចចូលបាន។ យើងអាចសន្និដ្ឋានថា ទួលនេះជាទួលប្រាសាទ ដែលមានលក្ខណៈដូចទួលអូរសោមក្នុងឃុំត្រពាំងប្រាសាទដែរ។



## ខ-ឃុំទំនប់ដាច់

ឃុំទំនប់ដាច់មានព្រំប្រទល់ខាងលិចជាប់ឃុំអូរស្វាយ, ខាងត្បូងជាប់ឃុំបាក់អន្លូង, ខាងជើងជាប់ភ្នំដងរែក និងខាងកើតជាប់ឃុំព្រះប្រឡាយ។ ឃុំទំនប់ដាច់មានផ្ទៃដី ទំហំ១៧២គីឡូម៉ែត្រក្រឡា ស្មើនឹង ១៧២៦០ ហិចតា។ ឃុំទំនប់ដាច់មានភូមិចំនួន៧គឺ៖ ភូមិទួលប្រាសាទ, ភូមិទួលចារ, ភូមិទំនប់ដាច់, ភូមិសែនសុខ, ភូមិជ័យនិវត្តន៍, ភូមិទួលពង្រ និងភូមិចារថ្មី។

### ២៦-ទួលប្រាសាទចារ

ទួលប្រាសាទចារ (X= ៤៤១៤៥៤, Y= ១៥៧៨០៦១០) ស្ថិតក្នុងភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ។ ជាប្រភេទប្រាសាទឥដ្ឋ មានគ្រឹះសង់ពីថ្មបាយក្រៀម បែរមុខទៅទិសខាងកើត ប្រហែល៨៨ដឺក្រេ។ នៅចំកណ្តាលទួលប្រាសាទ មានស្នាមជីករកវត្ថុបុរាណ ដែលយើងអាចមើលគ្រឹះនៃប្រាសាទ ដែលនៅរក្សាតួប្រាសាទសង់ពីឥដ្ឋ និងខឿនប្រាសាទសង់ពីថ្មបាយក្រៀម។ នៅលើទួលមានសិលាចារឹកមួយផ្ទាំង ទម្របដិមា បំណែកផ្តែរ និងបំណែកមេទ្វារ។



រូបលេខ២៦៨៖ ទួលប្រាសាទចារ



រូបលេខ២៦៩៖ សំណល់មេទ្វារប្រាសាទដែលមានអក្សចារឹកលើមេទ្វារនោះ



រូបលេខ២៧០៖ សំណល់តួប្រាសាទ


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ២៧-ប្រាសាទទំនប់ដាច់

ប្រាសាទទំនប់ដាច់ (X= ៤៤៣២២២, Y= ១៥៨១១០៣) ស្ថិតក្នុងភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ជាប្រាសាទស្ថាបនាពីឥដ្ឋ ស៊ុំទ្វារសង់ពីថ្មភក់។ តួប្រាសាទត្រូវគេលប់ដីកប់ ធ្វើឲ្យប្រាសាទមានកំពស់ទាប។ ការលើកដីលប់បែបនេះ ប្រហែលសង់នៅសម័យក្រោយ ដើម្បីលើកទីធ្លាឲ្យខ្ពស់ និងធំទូលាយ ក្នុងគោលបំណងប្រើប្រាស់ទីធ្លាសម្រាប់ប្រារព្ធពិធីសាសនាក្នុងសហគមន៍ ឬក្នុងភូមិ។ ការកែប្រែប្រាសាទព្រហ្មញ្ញសាសនា ទៅជាទីសក្ការៈបែបសាសនាពុទ្ធបានកើតឡើងនៅក្រោយសម័យអង្គរ នៅតាមតំបន់ជាច្រើនក្នុងប្រទេសកម្ពុជាក្នុងសម័យនោះ។ ប្រាសាទទំនប់ដាច់អាចប្រហែលដូចករណីខាងលើ។ ការលប់ដី ពង្រីកទីធ្លាឲ្យធំ បន្ទាប់មកសង់សំណង់បែបសាសនាពុទ្ធមួយ ចំណែកតួប្រាសាទក៏ក្លាយជាចេតិយទៅវិញ ធ្វើឡើងនៅសម័យកណ្តាល នៅពេលប្រទេសកម្ពុជាចាប់គោរពពុទ្ធសាសនាថេរវាទ។



រូបលេខ៧១៖ តួប្រាសាទទំនប់ដាច់សង់អំពីឥដ្ឋ

# ផែនទីបង្ហាញទីតាំងប្រាសាទតំបន់ដាច់ ស្ថិតនៅឃុំតំបន់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ២៨-ទួលត្រពាំងពោធិ៍

ទួលប្រាសាទត្រពាំងពោធិ៍(X= ៤៤៦៣៩៧, Y= ១៥៨០៤៦៩)ស្ថិតក្នុងភូមិត្រពាំងពោធិ៍ ឃុំទំនប់ដាច់។ ទួលប្រាសាទនេះមានគូទឹកប្រវែង១១ម៉ែត្រសង់ព័ទ្ធជុំវិញ។ ទួលប្រាសាទមានរាងចតុកោណកែង ដែលមានបណ្តោយស្របតាមអក្សកើតលិច ប្រវែង៤៣ម៉ែត្រ និងទទឹងស្របតាមអក្សជើងត្បូង ប្រវែង៣៣ម៉ែត្រ។ នៅចំកណ្តាលទួលមានស្នាមជីកកកាយរកវត្ថុបុរាណ។ យើងឃើញមានបំណែកថ្មសំណល់ប្រាសាទ ទម្រប់ដិមា និងថ្មដែលជាសមាសធាតុសំណង់ប្រាសាទស្ថិតនៅរាយប៉ាយលើទួល។

ទួលប្រាសាទត្រពាំងពោធិ៍មានលក្ខណៈដូចគ្នានឹងទួលប្រាសាទភូមិអូរសោម ក្នុងឃុំត្រពាំងប្រាសាទ និងទួលប្រសើរក្នុងឃុំបាក់អន្លង់។



រូបលេខ៧២៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទត្រពាំងពោធិ៍



រូបលេខ៧៣៖ ទម្រប់ដិមា ឬអាចជាទម្រលិង្គ



រូបលេខ៧៤៖ ដុំថ្មបាយក្រៀម និងថ្មភក់ដែលជាសមាសធាតុនៃសំណង់ប្រាសាទស្ថិតលើទួលត្រពាំងពោធិ៍


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

ជាសរុប នៅក្នុងឃុំទំនប់ដាច់មានប្រាសាទចំនួន២ និងទួលប្រាសាទ១។



## ច-ឃុំព្រះប្រឡាយ

ឃុំព្រះប្រឡាយមានព្រំប្រទល់ខាងលិចជាប់ឃុំទំនប់ដាច់, ខាងត្បូងជាប់ឃុំបាក់អន្លង, ខាងជើងជាប់ភ្នំដងរែក និងខាងកើតជាប់ព្រំប្រទល់ជាប់ឃុំកន្ទួត ស្រុកជាំក្សាន ខេត្តព្រះវិហារ។ ឃុំព្រះប្រឡាយមានផ្ទៃដី ទំហំ ២៥២គីឡូម៉ែត្រក្រឡា ស្មើនឹង១៩៩០៩ហិចតា។ ឃុំព្រះប្រឡាយមានភូមិចំនួន៨គឺ៖ ភូមិព្រះប្រឡាយ, ភូមិត្រាំចាន, ភូមអូរវែដ្ឋល, ភូមិបន្ទាយចាស់, ភូមិត្រាំប៉ោង, ភូមិត្រពាំងបី, ភូមិប្រាសាទក្រហម និងភូមិប្រាសាទក្រហមសែនជ័យ។

ប្រាសាទ និងទួលប្រាសាទរកឃើញនៅក្នុងឃុំព្រះប្រឡាយមានដូចជា៖

### ២៩-ប្រាសាទក្រហម

ប្រាសាទក្រហម (X= ៥៥១៦៣៩, Y= ១៥៧៨៣១៨) ស្ថិតក្នុងភូមិតេជោសែនជ័យ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ។ ប្រាសាទនេះមានតួសង់ពីឥដ្ឋ លាយជាមួយថ្មបាយក្រៀម និងគ្រឿងលម្អធ្វើពីថ្មភក់។ សំណល់ខ្លះៗមានដូចជា សសរពេជ្រ និងបំណែកថ្មភក់មួយចំនួនទៀត។ ប្រាសាទក្រហមមានកសិណព័ទ្ធជុំវិញ។ ប្រាសាទមានលក្ខណៈមួយគួរឲ្យចាប់អារម្មណ៍ គឺតួធ្វើពីឥដ្ឋបន្តដោយបន្ទប់លយសង់ពីថ្មបាយក្រៀម។ លក្ខណៈបែបនេះ និងសសរពេជ្ររាង៦ជ្រុង យើងអាចសន្និដ្ឋានថា យ៉ាងហោចណាស់ប្រាសាទក្រហមសង់ក្នុងសម័យអង្គរ ប្រហែលក្នុងសតវត្សទី១០ ឬសតវត្សទី១១។



រូបលេខ៧៥៖ តួប្រាសាទក្រហម



រូបលេខ៧៦៖ តួប្រាសាទក្រហម មើលពីទិសខាងកើត



រូបលេខ៧៧៖ សសរស្តម្ភដួលនៅមុខតួប្រាសាទក្រហម


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៣០-ទួលត្រាំចាន

ទួលត្រាំចាន (X= ៤៤៨៦៣៥, Y= ១៥៧៥១៩០) ស្ថិតក្នុងភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្ថិតនៅជិតផ្លូវជាតិពីត្រពាំងប្រាសាទឆ្ពោះទៅកាន់ស្រុកជាំក្សាន។ ទួលប្រាសាទត្រាំចានជាតួប្រាសាទមានគូទឹកព័ទ្ធជុំវិញ។ នៅលើទួលប្រាសាទមានសំណល់សមាសធាតុសំណង់ប្រាសាទដូចជា៖ ទម្រប‌ដិមា និងថ្មបាយក្រៀមជាសំណល់សំណង់ប្រាសាទ។

ទួលប្រាសាទត្រាំចានមានសណ្ឋានដូចនឹងទួលប្រាសាទត្រពាំងពោធិ៍ក្នុងឃុំទំនប់ដាច់, ទួលប្រាសាទភូមិអូរសោម ក្នុងឃុំត្រពាំងប្រាសាទ និងទួលប្រសើរ ក្នុងឃុំបាក់អន្លង់។



រូបលេខ៧៨៖ ទួលប្រាសាទត្រាំចាន



រូបលេខ៧៩៖ ទម្រប‌ដិមានៅលើទួលត្រាំចាន



រូបលេខ៨០៖ ដុំថ្មបាយក្រៀមដែលជាសមាសធាតុសំណង់ប្រាសាទនៅលើទួលត្រាំចាន

ផែនទីបង្ហាញទីតាំងប្រាសាទភ្នំទេន ស្ថិតនៅ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ៣១-ប្រាសាទត្រពាំងទឹម

ប្រាសាទត្រពាំងទឹម(X= ៤៤៨៣៤៣, Y= ១៥៦៧៥៣៦)ស្ថិតក្នុងឃុំព្រះប្រឡាយ ក្នុងតំបន់ព្រៃសហគមន៍។ ប្រាសាទនេះឲ្យឈ្មោះតាមត្រពាំងមួយស្ថិតនៅចំទិសខាងកើតនៃប្រាសាទ។ ត្រពាំងនោះឈ្មោះត្រពាំងទឹម។ ប្រាសាទត្រពាំងទឹមជាប្រាសាទមានតួតែមួយ សង់ពីថ្មភក់ មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ និងមានក្លោងទ្វារនៅគ្រប់ទិស។ ក្លោងទ្វារធំជាងគេគឺក្លោងទ្វារខាងកើត។ នៅខាងក្នុងកំពែង ជ្រុងឦសាន មានហោត្រៃមួយ ប៉ុន្តែត្រូវបាក់រលំ។ យើងមិនប្រទេះឃើញក្បាច់រចនានៅលើប្រាសាទនេះទេ។

បើយើងពិនិត្យលើលក្ខណៈសំណង់នៃប្រាសាទត្រពាំងទឹម សំណង់បែបនេះដូចគ្នានឹងប្រាសាទត្រពាំងប្រាសាទខាងជើង និងប្រាសាទនៅជិតប្រាសាទកូនចិន (ភ្នំសណ្តក)។ តាមរយៈលក្ខណៈសំណង់ យើងអាចសន្និដ្ឋានជាដំបូងថា ប្រាសាទនេះគឺជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ សង់នៅសតវត្សទី១៣។



រូបលេខ៨១៖ តួប្រាសាទត្រពាំងទឹម



រូបលេខ៨២៖ ក្លោងទ្វារខាងកើតប្រាសាទត្រពាំងទឹម



រូបលេខ៨៣៖ កំពែងនៃប្រាសាទត្រពាំងទឹមសង់ពីថ្មបាយក្រៀម


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៣២-ប្រាសាទស្វាក្រេស

ប្រាសាទស្វាក្រេស(X= ៤៥៤៦៣៥, Y= ១៥៦៨៧០៧)ស្ថិតក្នុងឃុំព្រះប្រឡាយ។ ប្រាសាទស្វាក្រេសមានតួប្រាសាទទោលសង់ពីថ្មបាយក្រៀម និងមានគូទឹកព័ទ្ធជុំវិញ។ នៅជិតតួប្រាសាទ យើងឃើញផ្តែរមួយមានក្បាច់រចនាជារឿងព្រះនារាយណ៍ផ្ទុំ និងមានជំបូលប្រាសាទរាងមូលនៅក្បែរនោះដែរ។ តាមរយៈក្បាច់លម្អលើផ្តែរ និងសំលៀកបំពាក់បដិមា យើងអាចសន្និដ្ឋានថា ប្រាសាទនេះប្រហែលជាសង់នៅចុងសតវត្សទី១០ ឬដើមសតវត្សទី១១។



រូបលេខ៨៤៖ តួប្រាសាទស្វាក្រេស



រូបលេខ៨៥៖ ផ្តែរប្រាសាទស្វាក្រេស នៅលើដីពីមុខតួប្រាសាទ



រូបលេខ៨៦៖ ថ្មភក់រាងមូលប្រហែលជាជំបូលប្រាសាទ

# ផែនទីបង្ហាញទីតាំងប្រាសាទស្នាព្រះ ស្ថិតនៅ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ



## ៣៣-ទួលប្រាសាទក្បាលឡាន

ទួលប្រាសាទក្បាលឡាន(X= ៤៥១៨៥១, Y= ១៥៧០០៩៧)ស្ថិតក្នុងឃុំព្រះប្រឡាយ។ ទួលប្រាសាទក្បាលឡានមានគូទឹកព័ទ្ធជុំវិញ មានទំហំ និងគូទឹកប្រវែង។ នៅលើទួលមានសំណល់ថ្មបាយក្រៀម ដែលជាសមាសធាតុសំណង់ និងថ្មភក់ជាទម្រមបដិមា។ នៅចំកណ្តាលសំណង់ថ្មបាយក្រៀម មានស្នាមជីករកវត្ថុបុរាណ។

ទួលប្រាសាទក្បាលឡានដូចជាគ្នានឹងទួលប្រាសាទត្រាំចានក្នុងឃុំព្រះប្រឡាយ, ទួលប្រាសាទត្រពាំងពោធិ៏ក្នុងឃុំទំនប់ដាច់, ទួលប្រាសាទភូមិអូរសោម ក្នុងឃុំត្រពាំងប្រាសាទ និងទួលប្រសើរក្នុងឃុំបាក់អន្លង។



រូបលេខ៨៧៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទក្បាលឡាន





រូបលេខ៨៨ និង៨៩៖ បំណែកថ្មភក់ដែលជាទម្រមបដិមា និងដុំថ្មបាយក្រៀមដែលជាសមាសធាតុនៃសំណង់ប្រាសាទ



ផែនទីបង្ហាញទីតាំងប្រាសាទក្បាលស្ពាន ស្ថិតនៅ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៣៤-ទួលប្រាសាទស្រែតាឃ៉ិន

ទួលប្រាសាទស្រែតាឃ៉ិន(X= ៤៤២១៨៧, Y= ១៥៧៣៣៦៦)ស្ថិតក្នុងឃុំព្រះប្រឡាយ។ ដោយសារទួលនេះមានព្រៃដុះយ៉ាងក្រាស់ យើងមិនអាចដឹងពីទំហំនៃទួល និងមិនអាចដឹងថាតើមានគូទឹក ឬគ្មាន? ទោះយ៉ាងណា យើងឃើញមានសំណល់ថ្មភក់ និងថ្មបាយក្រៀមមួយចំនួននៅលើទួលស្រែតាឃ៉ិននេះ។

ទួលប្រាសាទស្រែតាឃ៉ិន មានសណ្ឋានដូចនឹងទួលប្រាសាទក្បាលឡានក្នុងឃុំព្រះប្រឡាយ, ទួលប្រាសាទត្រាំចានក្នុងឃុំព្រះប្រឡាយ, ទួលប្រាសាទត្រពាំងពោធិ៍ក្នុងឃុំទំនប់ដាច់, ទួលប្រាសាទភូមិអូរសោមក្នុងឃុំត្រពាំងប្រាសាទ និងទួលប្រសើរក្នុងឃុំបាក់អន្លង់។



រូបលេខ៩០៖ ទិដ្ឋភាពទូទៅនៃទួលប្រាសាទស្រែតាឃ៉ិន



ស្ថិតនៅ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៣៥-ប្រាសាទអូររំដួល

ប្រាសាទអូររំដួល(X= ៤៤៤៩៥៩, Y= ១៥៧១៥៦១)ស្ថិតក្នុងភូមិអូររំដួល ឃុំព្រះប្រឡាយ។ ប្រាសាទអូររំដួលជាប្រាសាទទោល សង់ពីឥដ្ឋ និងមេទ្វារសង់ពីថ្មភក់។ ប្រាសាទមានគូទឹកសង់ព័ទ្ធជុំវិញ។ មានថ្មភក់រាយប៉ាយនៅក្បែរតួប្រាសាទ។ នៅចំពីមុខ តួប្រាសាទមានស្នាមជីករកវត្ថុបុរាណដូចគ្នានឹងប្រាសាទ ទួលប្រាសាទផ្សេងៗក្នុងស្រុកត្រពាំងប្រាសាទ។



រូបលេខ៩១៖ តួប្រាសាទអូររំដួល សង់ពីឥដ្ឋ និងមេទ្វារសង់ពីថ្មភក់



រូបលេខ៩២៖ ផ្នែកខាងក្នុងនៃតួប្រាសាទអូររំដួល



រូបលេខ៩៤៖ ថ្មភក់នៅរាយប៉ាយក្បែរតួប្រាសាទអូររំដួល


(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

## ៣៦-ទួលប្រាសាទត្រពាំងបី

ទួលប្រាសាទត្រពាំងបី(X= ៤៤៩៧៥៨, Y= ១៥៨៣៣៦១) ជាទួលប្រាសាទដែលមានមានលក្ខណៈសម្គាល់ណាមួយដូចទៅនឹងទួលប្រាសាទផ្សេងៗក្នុងស្រុកទាំងប្រាសាទទេ។ ទួលមានសណ្ឋានរាបស្មើ មិនមានគូទឹក ឬបំណែកថ្មភក់ ថ្មបាយក្រៀមនៅលើទួលទេ។ ប៉ុន្តែ នៅលើទួលនោះ អ្នកស្រុកកសាងខ្ទមអ្នកតាតូចមួយ ហើយនៅក្នុងខ្ទមអ្នកតាមានវត្ថុបុរាណមួយចំនួនដូចជា៖ ទម្រេបដិមា, មេទ្វារ និងវត្ថុ២ទៀតដែលមិនស្គាល់ថាជាអ្វី? វត្ថុទាំងពីរនោះ រាងដូចត្បាល់បុក។ វត្ថុមួយក្នុងចំណោមវត្ថុទាំងពីរ មានក្បាច់ត្របកឈូក។



រូបលេខ៩៤៖ ទិដ្ឋភាពនៃទួលប្រាសាទត្រពាំងបី ដែលមានខ្ទមអ្នកតាមួយ





រូបលេខ៩៥, ៩៦ និង៩៧៖ វត្ថុបុរាណរក្សាទុកក្នុងខ្ទមអ្នកតា ទុកជាគ្រឿងសក្ការៈ



(JICA GIS Dataset 2002)
Location Diagram
Coordinate System :
Projection : UTM
Spheroid : Everest
Datum : Indian60
Zone : 48N
Unit : Meter

ជាសរុប នៅឃុំព្រះប្រឡាយមានប្រាសាទចំនួន៤ និងទួលប្រាសាទចំនួន៤។ ក្នុងចំណោមប្រាសាទទាំង៤ គឺប្រាសាទមួយគឺប្រាសាទត្រពាំងទឹមគឺជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧។ ក្រៅពីប្រាសាទ និងទួលប្រាសាទ នៅមានទំនប់បុរាណប្រវែងលើសពី៣០០ម។ ទំនប់នេះប្រហែលសង់ឡើងដើម្បីរក្សាទឹក ដើម្បីធ្វើស្រែ។



## សន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និងរុករកប្រាសាទបុរាណ និងស្ថានីយបុរាណ ព្រមទាំងការធ្វើផែនទីស្ថានីយបុរាណនៅក្នុងស្រុកត្រពាំងប្រាសាទ ដែលចុះសិក្សាស្រាវជ្រាវដោយមន្ត្រីស្រាវជ្រាវនៃផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា បានរុករកឃើញប្រាសាទ និងទួលប្រាសាទ ឬគ្រឹះប្រាសាទចំនួន២៩, ស្ថានីយយកថ្មបាយក្រៀមចំនួន២កន្លែង, ស្ថានីយយកថ្មភក់ និងសិប្បកម្មថ្មភក់១កន្លែង, ថ្មគោលចំនួន៣ ព្រមទាំងភូមិបុរាណ, ត្រពាំងបុរាណ និងទំនប់បុរាណមួយចំនួនទៀត។

ចំនួនប្រាសាទ និងស្ថានីយបុរាណនៅតាមឃុំនីមួយៗគឺៈ នៅក្នុងឃុំត្រពាំងប្រាសាទមានប្រាសាទ និងទួលប្រាសាទចំនួន១៣, ស្ថានីយយកថ្មបាយក្រៀមចំនួន២កន្លែង, ស្ថានីយយកថ្មភក់ និងសិប្បកម្មចម្លាក់ ថ្មភក់ចំនួន១កន្លែង និងថ្មគោលចំនួន២។ ក្រៅពីនោះនៅមានទំនប់បុរាណចំនួន៣។ រីឯនៅក្នុងឃុំអូរស្វាយវិញ មានប្រាសាទ និងទួលប្រាសាទចំនួន៤ និងថ្មគោល១។ ចំណែកនៅក្នុងឃុំផ្អាវមានទីដ្ឋានបុរាណ គឺជាភូមិបុរាណដែលមនុស្សធ្លាប់រស់នៅ និងជីកត្រពាំង។ ចំពោះឃុំបាក់អន្លូងមានទួលប្រាសាទតែមួយគត់។ នៅក្នុងឃុំទំនប់ដាច់មានប្រាសាទចំនួន២ និងទួលប្រាសាទ១។ ឃុំចុងក្រោយ គឺនៅឃុំព្រះប្រឡាយមានប្រាសាទចំនួន៤ និងទួលប្រាសាទចំនួន៤។

ក្នុងចំណោមប្រាសាទទាំង២៩ដែលរៀបរាប់ខាងលើ ប្រាសាទចំនួន៣ដែលជាមន្ទីរពេទ្យរបស់ ព្រះបាទជ័យវរ្ម័នទី៧ គឺប្រាសាទត្រពាំងប្រាសាទខាងជើងក្នុងឃុំត្រពាំងប្រាសាទ, ប្រាសាទជិតប្រាសាទកូនចិនក្នុងតំបន់ភ្នំសណ្តក ក្នុងឃុំត្រពាំងប្រាសាទដែលនៅជិតព្រំដែនខេត្តព្រះវិហារ និងប្រាសាទត្រពាំងទឹមក្នុងឃុំព្រះប្រឡាយ។ ដូច្នេះ យើងអាចដឹងថា ប្រាសាទទាំងបីកសាងក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងសតវត្សទី១៣។

យើងអាចសិក្សាពីអាយុកាលនៃប្រាសាទមួយចំនួន ដែលបានរកឃើញតាមរយៈក្បាច់លម្អលើប្រាសាទ ជាពិសេសនៅលើផ្តែរ ហោជាង សសរផ្តោប ឬសសរស្តម្ភជាដើម។ ពុំនោះ បើរកឃើញសិលាចារឹក នៅជាប់នឹងប្រាសាទ ការសិក្សាពីអាយុកាលនៃការសាងសង់រឹតតែមានភាពងាយស្រួល ហើយប្រាកដជានឹងបានដឹងច្បាស់លាស់ពីអាយុកាលនោះ។ ជាទូទៅ យើងមិនមានប្រទះឃើញសិលាចារឹកនៅជាប់នឹងប្រាសាទឡើយ លើកលែងតែប្រាសាទភ្នំសណ្តក ដែលមានសិលាចារឹកចារនៅលើក្លោងទ្វារនៃកំពែងទី២។ ក្នុងសិលាចារឹកនោះមានចារពីព្រះនាមរបស់ព្រះបាទសូរ្យវរ្ម័នទី១។ ដូចនេះ អាយុកាលនៃការសាងសង់ប្រាសាទភ្នំសណ្តកគឺនៅក្នុងសតវត្សទី១១ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១។ ក៏ប៉ុន្តែ ប្រាសាទភ្នំសណ្តក គឺជាប្រភេទបណ្តុំប្រាសាទដែលមានការសាងសង់ពីរាជស្តេចមួយទៅរាជស្តេចមួយទៀត។ ប្រាសាទភ្នំសណ្តកប្រហែលចាប់ផ្តើមកសាងតាំងពីដើមសតវត្សទី១០មកម្ល៉េះ ហើយបន្តសាងសង់រហូតដល់សតវត្សទី១២។ ភាពច្បាស់លាស់អំពីការសាងសង់ប្រាសាទភ្នំសណ្តកនេះទាមទាការសិក្សាលម្អិត ដោយមានពេលវេលាច្រើន។

ប្រាសាទប្រាសាទត្រពាំងខាងត្បូងប្រហែលស្ថាបនានៅសតវត្សទី១០ ក្នុងរចនាបថកោះកេរ ឬរចនាបថប្រែរូប។ ប្រាសាទរលំទឹកខ្មៅ និងប្រាសាទល្វើកជ្រៃក៏ប្រហែលសង់ក្នុងសតវត្សទី១០ដែរ ដោយសារប្លង់ប្រាសាទទាំងពីរដូចគ្នានឹងប្រាសាទត្រពាំងប្រាសាទខាងត្បូង ទោះបីជាពុំមានក្បាច់លម្អលើប្រាសាទក៏ដោយ។

ប្រាសាទ និងទួលប្រាសាទមួយចំនួនទៀត យើងមិនអាចសន្និដ្ឋានពីអាយុកាលនៃការសាងសង់បានទេ។ ការសិក្សាធ្វើកំណាយបែបបុរាណវិទ្យា រួមផ្សំជាមួយវិធីសាស្ត្រទំនើបៗថ្មីៗ នឹងរកចម្លើយនៃអាយុកាលសាងសង់បាន ក៏ប៉ុន្តែ ទាមទារថវិកា និងពេលវេលាគ្រប់គ្រាន់។

យោងតាមទិន្នន័យដែលរកឃើញ យើងអាចសន្និដ្ឋានជាដំបូងថា ការតាំងទីលំនៅ ក៏ដូចជាការកសាងប្រាសាទនៅតំបន់ត្រពាំងប្រាសាទអាចនឹងចាប់ផ្តើមនៅចុងសតវត្សទី៩, ដើមសតវត្សទី១០, សតវត្សទី១១, សតវត្សទី១២ និងសតវត្សទី១៣។ ការប្តូររាជធានីរបស់ព្រះបាទជ័យវរ្ម័នទី៤ នៅក្នុងសតវត្សទី១០ ពិតជាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតំបន់ត្រពាំងប្រាសាទ។ គឺនៅពេលនោះហើយដែលព្រះអង្គបានកសាងរាជធានីកោះកេរឲ្យថ្កុំថ្កើនឡើង ហើយក៏មិនភ្លេចពង្រីកអំណាចឆ្ពោះទៅកាន់ភាគខាងជើង និងខាងជើងឈៀងខាងកើត។ ប្រាសាទមួយចំនួនបានកសាងក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ ហើយជាពេលដែលធ្វើឲ្យតំបន់នេះមានការចាប់អារម្មណ៍ និងបន្តពង្រីកទៅកាន់តំបន់ជិតខាងតទៅទៀត។

តំបន់នេះរីកចម្រើនទៅបានដោយសារពឹងផ្អែកជាចម្បងលើធនធានធម្មជាតិ គឺអនុផលព្រៃឈើទាំងឡាយ ដូចជាឈើ, ជ័រឈើ, ឈើសម្រាប់ថ្នាំ, សត្វជាដើម។ ការធ្វើទំនាក់ទំនងរបស់មនុស្សនៅតំបន់នេះពឹងផ្អែកលើផ្លូវគោកជាចម្បង ទោះបីមានប្រព័ន្ធអូរជាច្រើនយ៉ាងណាក៏ដោយ ពីព្រោះអូរទាំងនោះមានទំហំតូច និងមិនមានទឹកជាប្រចាំពេញមួយឆ្នាំ និងមិនមានទន្លេសម្រាប់ជួយសម្រួលដល់គមនាគមន៍បានឡើយ។ យើងដឹងថា ផ្លូវបុរាណមួយខ្សែបានកសាងពីរាជធានីអង្គរមកបឹងមាលា ហើយបន្តពីបឹងមាលាកាត់រាជធានីកោះកេរ ហើយបន្តទៅកាន់ប្រាសាទអ្នកបួស មុននឹងទៅដល់ប្រាសាទវត្តភូប្រទេសលាវ។ ផ្លូវបុរាណមួយខ្សែនេះពិតជាមានទំនាក់ទំនងជាមួយតំបន់ត្រពាំងប្រាសាទ។ ទោះបីមិនមានផ្លូវធំសង់បំបែកពីផ្លូវបុរាណដើម្បីភ្ជាប់ទៅតំបន់ត្រពាំងប្រាសាទ យ៉ាងហោចណាស់គេកសាងផ្លូវមួយភ្ជាប់ទៅផ្លូវបុរាណនោះ។ ដូច្នេះមនុស្សទាំងឡាយអាចធ្វើដំណើរចេញចូលពីតំបន់មួយទៅតំបន់មួយ ពីត្រពាំងប្រាសាទបាន។ ដូចគ្នានេះដែរ ធនធានព្រៃឈើទាំងឡាយអាចធ្វើពាណិជ្ជកម្មបានតាមរយៈផ្លូវបុរាណមួយខ្សែនេះ។ ធនធានទាំងនេះក៏អាចដោះដូរក្នុងរង្វង់តំបន់ជួរភ្នំដងរែកដូចគ្នាក៏បានដែរ។

ការធ្វើកសិកម្មស្រូវប្រាកដជាមាននៅតំបន់ត្រពាំងប្រាសាទ ក៏ប៉ុន្តែមិនមានលក្ខណៈធំដូចនៅរាជធានីអង្គរទេ។ ទីនេះជាតំបន់ព្រៃឈើក្រាស់ ពិបាកក្នុងការរានដីធ្វើកសិកម្ម។ ធនធានព្រៃឈើមានស្រាប់ មិនចាំបាច់ពិបាកក្នុងការរានដី ដោយកាប់ដើមឈើធំៗ ដើម្បីយកដីធ្វើស្រែនោះទេ។ ជាងនេះទៀត ការធ្វើកសិកម្មស្រូវមិនអាចប្រកួតប្រជែងជាមួយអ្នកនៅតំបន់អង្គរបានឡើយ ដោយហេតុអង្គរមានបារាយណ៍ធំៗដែលអាចផ្គត់ផ្គង់ទឹកសម្រាប់ធ្វើស្រែយ៉ាងបរិបូរណ៍។ ផ្ទុយទៅវិញ បើនិយាយពីធនធានព្រៃឈើ តំបន់អង្គរក៏មិនអាចប្រកួតប្រជែងជាមួយតំបន់ត្រពាំងប្រាសាទបានដែរ។ ដោយសារកត្តាធនធានព្រៃឈើនេះហើយ ទើបតំបន់ត្រពាំងប្រាសាទចេះតែរីកចម្រើន និងបន្តការរស់នៅរហូតដល់សតវត្សទី១៣។ ម្យ៉ាងទៀត វត្តមានមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ទាំងបីបញ្ជាក់ថា ព្រះអង្គមើលឃើញពីសក្តានុពលនៃតំបន់ ទើបព្រះអង្គកសាងមន្ទីរពេទ្យទាំងនេះដើម្បីគ្រប់គ្រង និងពង្រឹងអំណាចរបស់ព្រះអង្គនៅទីនេះ។

ក្រោយមកនៅពេលរាជធានីខ្មែរប្តូរទៅចតុមុខនៅសតវត្សទី១៥ តំបន់នេះហាក់ដូចលែងមានសកម្មភាពដូចមុន។ ទំនាក់ទំនងពាណិជ្ជកម្មរវាងតំបន់នេះនឹងតំបន់អង្គរត្រូវរាំងស្ទះ ព្រោះរាជធានីលែងនៅអង្គរទៀត ផ្លូវបុរាណឆ្ពោះទៅកាន់រាជធានីអង្គរប្រហែលមិនសូវដំណើរការ ម្ល៉ោះហើយ ធនធានព្រៃឈើដែលធ្លាប់ដោះដូរបាន ប្រហែលលែងមានចង្វាក់ពាណិជ្ជកម្មបានតទៅទៀត ធ្វើឲ្យសេដ្ឋកិច្ចនៅតំបន់នេះធ្លាក់ចុះ។

ទាក់ទងនឹងការងារថែរក្សាគាំពារប្រាសាទ និងស្ថានីយបុរាណ កិច្ចការការពារ និងថែទាំងប្រាសាទ ព្រមទាំងស្ថានីយបុរាណជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ទោះបីនេះជាការទទួលបន្ទុករបស់ក្រសួងសមត្ថកិច្ច គឺក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្តី។ កេរដំណែលប្រាសាទទាំងអស់ ក៏ដូចជាស្ថានីយបុរាណក្នុង

ស្រុកត្រពាំងប្រាសាទគួរត្រូវទទួលស្គាល់ពីគុណតម្លៃរបស់កេរដំណែលទាំងនោះ និងត្រូវចូលរួមថែរក្សា ការពារ និងត្រូវចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីឈានទៅរកការរៀបចំផែនការអភិវឌ្ឍតំបន់ទេសចរណ៍ផ្សេងៗ ឲ្យមានច្រើនក្រៅពីឧទ្យានអង្គរដែលទទួលទេសចរច្រើន អាចនឹងមានបញ្ហាគ្រោះថ្នាក់ដល់ប្រាសាទក្នុងឧទ្យានអង្គរទាំងមូល។ ដូច្នេះ គួររៀបចំតំបន់ទេសចរណ៍វប្បធម៌ ឲ្យបានច្រើនក្រៅពីឧទ្យានអង្គរ។

ដោយយល់ដឹងពីតម្លៃកេរដំណែលដែលជាសម្បត្តិវប្បធម៌ជាតិ អាជ្ញាធរស្រុកត្រពាំងប្រាសាទបានចាប់ផ្តើមអនុវត្តកិច្ចការការពារប្រាសាទនៅក្នុងស្រុករបស់ខ្លួន។ អាជ្ញាធរស្រុកបានចាត់ឲ្យមេឃុំ និងមេភូមិចាប់ផ្តើមបញ្ឈប់រាល់សកម្មភាពកាប់ដើមឈើនៅក្នុងបរិវេណប្រាសាទ, ការជីកកកាយរកកំណប់នៅក្នុងបរិវេណប្រាសាទ។ ជាងនេះទៀត មេឃុំ និងមេភូមិត្រូវរៀបចំកំណត់ព្រំដែនរបស់ប្រាសាទឲ្យបានច្បាស់លាស់ លែងឲ្យមានការកាន់កាប់ដីក្បែរប្រាសាទជាសម្បត្តិឯកជន។ ក្នុងករណីមានសំណើរកសាងវត្ត ត្រូវសង់វត្តនៅចម្ងាយ៥០០ម៉ែត្រពីប្រាសាទ។

យើងខ្ញុំយល់ថា ការចូលរួមថែរក្សាការពារប្រាសាទបុរាណពីសំណាក់អាជ្ញាធរដែនដីពិតជាមានប្រសិទ្ធភាពខ្ពស់ ព្រោះអស់លោកគឺជាអ្នករស់នៅមូលដ្ឋានស្រាប់ និងមានអំណាចគ្រប់គ្រងដែនដី ដែលជាអំណោយផលក្នុងការអនុវត្តកិច្ចការអភិរក្សប្រាសាទ។ ស្របគ្នានេះដែរ ការថែរក្សាសម្បត្តិវប្បធម៌នៅក្នុងមូលដ្ឋានខ្លួន គឺមានន័យថា ថែរក្សាសម្បត្តិផ្ទាល់របស់អាជ្ញាធរដែនដីនោះ។ នោះហើយគឺជាស្នាដៃ កិត្តិយស និងកិត្តិស័ព្ទដែលអាជ្ញាធរដែនដីនោះទទួលបាន។ ការអភិរក្ស និងអភិវឌ្ឍន៍ប្រាសាទ ព្រមទាំងស្ថានីយបុរាណបានជោគជ័យ វានឹងនាំទៅដល់ការចាប់អារម្មណ៍ពីសំណាក់ទេសចរជាតិ ក៏ដូចជាអន្តជាតិ។ ពេលនោះ ទេសចរនឹងធ្វើដំណើរទៅទស្សនាប្រាសាទ ទេសចរនឹងចំណាយថវិកាស្នាក់នៅ បរិភោគ និងការធ្វើដំណើរជាដើម។ ដូចនេះ ប្រជាជន ក៏ដូចជាអាជ្ញាធរនៅទីនោះ គឺជាអ្នកបានទទួលផលពីទេសចរទាំងនោះ។ នេះហើយគឺជានយោបាយឈ្នះឈ្នះ ប្រាសាទក៏នៅគង់វង្ស ចំណូលថវិកាក៏ទទួលបានទៅដល់អ្នកដែលពាក់ព័ន្ធនឹងប្រាសាទ។

# អនុសាសន៍

ក្រោយពីធ្វើការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យដែលមាន យើងខ្ញុំជាមន្ត្រីស្រាវជ្រាវជំនាញបុរាណវត្ថុវិទ្យានៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា មើលឃើញពីបញ្ហា និងដំណោះស្រាយផ្សេងៗដើម្បីកិច្ចការស្រាវជ្រាវទៅថ្ងៃខាងមុខ និងកិច្ចការអភិរក្សដើម្បីអភិវឌ្ឍ ដែលការងារអភិរក្សនេះជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលគួរប្រតិបត្តិនាពេលអនាគត។

យើងខ្ញុំសូមមានសំណើរ និងអនុសាសន៍ដូចរៀបរាប់ខាងក្រោម៖

១. លទ្ធផលនៃការស្រាវជ្រាវ និងការរកឃើញប្រាសាទទាំង២៩, ស្ថានីយយកថ្មបាយក្រៀមចំនួន២, ស្ថានីយយកថ្មភក់ និងសិប្បកម្មថ្មភក់ចំនួន១, ថ្មគោលចំនួន៣, ទំនប់បុរាណ, ភូមិដ្ឋានបុរាណ ព្រមទាំងត្រពាំងបុរាណជាច្រើនទៀត គឺជាទិន្នន័យថ្មី នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ មូលហេតុដែលមិនមានការសិក្សាស្រាវជ្រាវពីសំណាក់ស្ថាប័នផ្សេងៗ ទោះស្ថាប័នជាតិក្តី អន្តរជាតិក្តី នៅតំបន់នេះ គឺដោយសារទីតាំងនេះធ្លាប់ជាតំបន់សង្គ្រាមប្រយុទ្ធគ្នា បន្សល់គ្រាប់មីន និងអាវុទ្ធជាតិផ្ទុះជាច្រើន។ យើងរំពឹងថា នៅមានប្រាសាទនិងស្ថានីយបុរាណជាច្រើនទៀតនៅក្នុងស្រុកផ្សេងទៀតក្នុងខេត្តឧត្តរមានជ័យ ជាពិសេសស្រុកដែលស្ថិតនៅតាមជួរភ្នំដងរែក។

ដូច្នេះ យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល តាមរយៈទីស្តីការគណរដ្ឋមន្ត្រី សូមបន្តរឧបត្ថម្ភដល់មន្ត្រីស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីបានសិក្សាស្រាវជ្រាវរុករកប្រាសាទ និងស្ថានីយបុរាណនៅក្នុងទូទាំងខេត្តឧត្តរមានជ័យ។ លទ្ធផលនៃការសិក្សាគម្រោងនេះ នឹងជាទិន្នន័យដ៏មានសារៈប្រយោជន៍ចំពោះជាតិកម្ពុជា និងជាមោទនភាពជាតិ ជាពិសេស ការរកឃើញប្រាសាទថ្មីៗ នឹងឈានទៅដល់ការងារអភិរក្ស និងអភិវឌ្ឍ។ ម៉្យាងវិញទៀត ទីតាំងប្រាសាទទាំងនោះគឺស្ថិតនៅតាមជួរភ្នំដងរែក គឺនៅតាមព្រំដែនកម្ពុជា-សៀម ដែលជាចំណែកមួយនៃការចូលរួមអភិវឌ្ឍជាតិនៅតាមព្រំដែន។

២. តំបន់ភ្នំសណ្តកគឺជាទីតាំងអស្ចារ្យ គិតតាំងពីប្រាសាទបុរាណចំនួន៤, ភូមិបុរាណ, ត្រពាំងបុរាណ, និងទំនប់បុរាណ ព្រមទាំងសម្បត្តិធម្មជាតិ រួមមានព្រៃព្រឹក្សា និងពូជសត្វព្រៃជាច្រើនប្រភេទ។ ដោយមើលឃើញពីសក្តានុពលនៃតំបន់ភ្នំសណ្តក យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល ជាពិសេសដល់អាជ្ញាធរពាក់ព័ន្ធ សូមមេត្តារៀបចំផែនការអភិរក្សតំបន់ភ្នំសណ្តកនេះ ព្រមទាំងសង់ផ្លូវចេញពីភូមិពានមាស ឃុំត្រពាំងប្រាសាទឆ្ពោះទៅកាន់ទីតាំងនោះ។ បច្ចុប្បន្ននេះ មិនមានផ្លូវទៅដល់ភ្នំសណ្តកទេ។ យើងអាចធ្វើដំណើរទៅភ្នំសណ្តកបានតាមផ្លូវដើររបស់អ្នកស្រុកធ្លាប់ធ្វើដំណើរទៅមកតាមរយៈម៉ូតូ។ ប្រជាជននៅក្នុងស្រុកមានការចាប់អារម្មណ៍ចំពោះប្រាសាទនេះខ្លាំងណាស់ រហូតមានកម្មវិធីនាំសិស្សបឋមសិក្សាទស្សនាប្រាសាទភ្នំសណ្តក ដោយធ្វើដំណើរថ្មើជើងពីភូមិពានមាស ទៅកាន់ភ្នំសណ្តក។ ធម្មជាតិរួមផ្សំជាមួយសម្បត្តិវប្បធម៌ជុំវិញភ្នំសណ្តក ពិតជាមានសម្រស់ទាក់ទាញចិត្តមនុស្សឲ្យចង់ទស្សនា។ និយាយឲ្យខ្លី ការអភិរក្ស និងអភិវឌ្ឍតំបន់ភ្នំសណ្តក នឹងធ្វើឲ្យតំបន់នេះក្លាយជារមណីយដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិនៃប្រទេសកម្ពុជា។

មន្ត្រីស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈត្រៀមខ្លួនជាស្រេចក្នុងការចូលរួមការងារអភិរក្សនិងអភិវឌ្ឍន៍តំបន់ភ្នំសណ្តក ក្នុងវិស័យបច្ចេកទេស និងរាល់លទ្ធភាពទាំងឡាយណាដែលយើងខ្ញុំអាចអនុវត្តបាន។ ជានិច្ចកាល យើងខ្ញុំរីករាយនឹងឃើញប្រាសាទបុរាណ ស្ថានីយបុរាណក្នុងប្រទេសកម្ពុជាបានថែរក្សា និងអភិរក្សបានគង់វង្សតរៀងទៅ។